**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jun-2011, 11:37
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# សារណាបន្ថែមរបស់ លោក អៀង សារី លើអញ្ញត្រកម្មរបស់គាត់ ដែលធ្វើតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (ការលើកលែងទោស និង ការអនុគ្រោះទោស)

---

**ដាក់ដោយ:**

**សហមេធាវី:**
អាង ឧត្តម
Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **ឆូ មណី**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង **យូរ ឧត្តរា**
ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា:**
ជា លាង
Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**
**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

អនុលោមតាមអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង[1] លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("ក្រុមមេធាវីការពារក្តី") សូមដាក់សារណាបន្ថែមមួយនេះ ទៅលើអញ្ញត្រកម្មរបស់ខ្លួនប្រឆាំងនឹងយុត្តាធិការរបស់អ.វ.ត.ក ដោយផ្អែកលើព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោសលើលោក អៀង សារី។ សារណាបន្ថែមមួយនេះ រួមបញ្ចូលនូវរាល់ទឡ្ហីករណ៍មុនៗទាំងអស់ពាក់ព័ន្ធនឹងបញ្ហាទាំងនេះ[2]។

## I. សេចក្តីផ្តើម និង សេចក្តីសង្ខេបលើទឡ្ហីករណ៍

១. អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញក្រុមមេធាវីការពារក្តីឲ្យដាក់សារណាលើបីចំណុច៖

ក. សំណៅឯកសារបកប្រែនានានៃព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោស ដែលក្រុមមេធាវីការពារក្តី និងអង្គបុរេជំនុំជម្រះ បានយកមកធ្វើជាសំអាង និងសំណៅបកប្រែថ្មីមួយដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឲ្យ។

ខ. "តើការលើកលែងទោស/ការអនុគ្រោះទោស លោក អៀង សារី ស្របតាមរដ្ឋធម្មនុញ្ញ (មាត្រា ២៧ និង មាត្រា ៩០ ថ្មី នៃរដ្ឋធម្មនុញ្ញ) ដែរឬទេ និង

គ. សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងនឹង

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី ការដាក់សារណាអញ្ញត្រកម្មបន្ថែម (ពាក់ព័ន្ធនឹងការអនុគ្រោះទោស និង ការលើកលែងទោស) ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០១១ ឯកសារលេខ E51/8 ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង")។

[2] *សូមមើល* សារណារបស់លោក អៀង សារី អនុលោមទៅតាម*សេចក្តីសម្រេចទៅសំណើជាបន្ទាន់របស់សហមេធាវីសុំអោយមានការពន្យារពេលសមហេតុផលសម្រាប់ការដាក់ការតតាំងនឹងបញ្ហាយុត្តាធិការ* ចុះថ្ងៃទី ៧ មេសា ២០០៨ ឯកសារលេខ C22/I/26 ប្រតិចារឹក នៃសវនាការលើការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី ១-៤ ថ្ងៃទី ៣០ មិថុនា ២០០៨។ ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្តាពររបស់ កសព អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម ចុះថ្ងៃទី 1 កញ្ញា ២០១០ ឯសារលេខ D390/1/2/1.3 កថាខណ្ឌ ១៦០-១៦៩។ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ តុលា ២០១០ ឯកសារលេខ D427/1/6 កថាខណ្ឌ ៤២-១០២ ("បណ្តឹងឧទ្ធរណ៍របស់ អៀង សារី")។ ចម្លើយតបរបស់លោក អៀង សារី ទៅនឹងការឆ្លើយតបរួមរបស់ សហព្រះរាជអាជ្ញា ទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៦ ធ្នូ ២០១០ ឯកសារលេខ D427/1/23 កថាខណ្ឌ ២៦-៣២ ។ ចម្លើយតបរបស់ អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមេធាវីគ្មានព្រំដែន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/1/24 កថាខណ្ឌ ២៨-២៩។

ដីកាដំណោះស្រាយ[3] ប្រសិនបើសាលដីកានោះនាំមកនូវទឡ្ហីករណ៍ថ្មីៗថែមទៀត[4]។

២. ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីសូមដាក់សារណាដូចខាងក្រោម៖

ក. សំណៅបកប្រែនៃព្រះរាជប្រទានការលើកលែងទោស/ការអនុគ្រោះទោស ដែលក្រុមមេធាវីការពារក្តីបានប្រើធ្វើជាសំអាង គឺជាសំណៅត្រឹមត្រូវ ហើយត្រូវតែបកស្រាយឯកសារនេះដោយផ្តល់ប្រយោជន៍ច្រើនបំផុតដល់លោក អៀង សារី។

ខ. ការលើកលែងទោស/ការអនុគ្រោះទោស ស្របតាមរដ្ឋធម្មនុញ្ញ៖

១. ការលើកលែងទោស/ការអនុគ្រោះទោស ត្រូវបានផ្តល់ឲ្យ លោក អៀង សារី ដោយស្របទៅនឹងរដ្ឋធម្មនុញ្ញ។

២. រដ្ឋធម្មនុញ្ញមិនដាក់កំហិតលើប្រភេទឧក្រិដ្ឋកម្ម ដែលអាចទទួលការអនុគ្រោះទោស ឬ លើកលែងទោសឡើយ។

៣. ដោយហេតុថាតុលាការជាតិពិចារណាទៅលើការលើកលែងទោស/ការអនុគ្រោះទោសថ្នាក់ជាតិ កាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា មិនជះឥទ្ធិពលលើសុពលភាពនៃការលើកលែងទោស/ការអនុគ្រោះទោសឡើយ។

៤. បើទោះជា អ.វ.ត.ក ត្រូវបានចាត់ទុកជាតុលាការដែលលក្ខណៈជាអន្តរជាតិក៏ដោយ ក៏ការលើកលែងទោស/ការអនុគ្រោះទោស នៅតែមានសុពលភាពដដែល។

គ. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំក្នុងការសម្រេចថា វិសាលភាពនៃការលើកលែងទោស/ការអនុគ្រោះទោស មិនបានរារាំងដល់ការកាត់សេចក្តី លោក អៀង សារី នៅ អ.វ.ត.ក៖

១. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំក្នុងការសម្រេចថា អានុភាពតែមួយគត់នៃការលើកលែងទោស គឺលុបចោលការផ្តន្ទាទោសដែល លោក អៀង សារី បានទទួលនៅក្នុងឆ្នាំ ១៩៧៩ ហើយ

---

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30 (“សាលដីកា អ.ប.ជ”)។

[4] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង។

២. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំនៅក្នុងការសម្រេចថា ការអនុគ្រោះទោសមិនរារាំងដល់ការកាត់សេចក្តីលើ លោក អៀង សារី នៅ អ.វ.ត.ក។

## II. **ទន្លីករណ៍**

ក. **សំណៅបកប្រែនៃព្រះរាជប្រទានការលើកលែងទោស/ការអនុគ្រោះទោស ដែលក្រុមមេធាវីការពារក្តីបានប្រើធ្វើជាសំអាង គឺជាសំណៅត្រឹមត្រូវ ហើយសំណៅនេះត្រូវតែបកស្រាយដោយផ្តល់ប្រយោជន៍ច្រើនបំផុតឱ្យទៅ លោក អៀង សារី**

៣. នាពេលបច្ចុប្បន្ននេះ មានសំណៅបកប្រែនៃព្រះរាជប្រទានការលើកលែងទោស/ការអនុគ្រោះទោស ជាភាសាអង់គ្លេសយ៉ាងហោចណាស់ចំនួនបី៖

ក. សំណៅបកប្រែដែលក្រុមមេធាវីការពារក្តីយកមកប្រើជាសំអាង ដែលជាសំណៅមាននៅក្នុងកម្រងឯកសារច្បាប់របស់ អ.វ.ត.ក[5] ដែលបកប្រែដោយរាជរដ្ឋាភិបាលកម្ពុជា[6]។

ខ. សំណៅបកប្រែដែលផ្តល់ឱ្យដោយអង្គបុរេជំនុំជម្រះ[7] និង

---

[5] បណ្តុំឯកសារច្បាប់ អ.វ.ត.ក មាននៅក្នុងឃ្លាំងផ្ទុកឯកសារ Drive G ដែលរាល់ភាគី និង អង្គជំនុំជម្រះទាំងអស់នៃ អ.វ.ត.ក អាចចូលមើលបាន។ សំណៅបកប្រែមួយនេះ ក៏ជាសំណៅបកប្រែដំបូងគេបង្អស់ដែលបានដាក់ចូលទៅក្នុងសំណុំរឿង។ *សូមមើល* ឯកសារលេខ D366/7.1.191។

[6] សំណៅបកប្រែមួយនេះត្រូវបានប្រើប្រាស់ដោយ ក្រុមការងារពិសេសរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការណ៍ជាមួយអ្នកជំនាញផ្នែកច្បាប់បរទេស និងការរៀបចំកិច្ចដំណើរការនីតិវិធីសម្រាប់កាត់សេចក្តីអ្នកដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលបានធ្វើការជាមួយសហគមន៍អន្តរជាតិលើការធ្វើពង្រាងច្បាប់ និង លិខិតុបករណ៍នានា ដើម្បីប្រើប្រាស់នៅ អ.វ.ត.ក។ *សូមមើល* http://www.eccc.gov.kh/en/chronologies/royal-government-created-its-task-force-cooperation-foregin-legal-experts-and-preparat សំណៅបកប្រែមាត្រា ១ មានដូចខាងក្រោម៖

> ត្រូវបានលើកលែងទោសអោយ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតបង់ និង រឹបអូស ទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង អនុគ្រោះទោសចំពោះការកាត់សេចក្តីក្រោមច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤...

[7] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/73 (“សាលដីការបស់ អ.ប.ជ លើការឃុំខ្លួនបណ្តោះអាសន្ន”) កថាខណ្ឌទី ២៧។ សាលដីការបស់

គ. សំណៅបកប្រែដែលផ្ដល់ឲ្យដោយអង្គជំនុំជម្រះសាលាដំបូង[8]។

៤. ភាពខុសគ្នាសំខាន់ៗរវាងសំណៅបកប្រែទាំងនេះ ត្រង់មាត្រា ១ នោះគឺ[9]៖

ក. សំណៅបកប្រែរបស់ក្រុមមេធាវីការពារក្ដី និងអង្គជំនុំជម្រះសាលាដំបូង យោងទៅលើ "ការលើកលែងទោស" នៅក្នុងឃ្លាទីមួយនៃមាត្រានេះ ខណៈពេលដែលសំណៅបកប្រែរបស់អង្គបុរេជំនុំជម្រះយោងទៅលើ "ការអនុគ្រោះទោស"[10] និង

ខ. សំណៅបកប្រែរបស់ក្រុមមេធាវីការពារក្ដី និង អង្គបុរេជំនុំជម្រះ យោងទៅលើ "ការអនុគ្រោះទោសចំពោះការកាត់សេចក្ដីក្រោម [ច្បាប់ឆ្នាំ ១៩៩៤]" ខណៈពេលដែលសំណៅបកប្រែរបស់អង្គជំនុំជម្រះ យោងទៅលើ "ការលើកលែងទោស... ចំពោះការផ្ដន្ទាទោសណាមួយ ដែលមានចែងនៅក្នុង [ច្បាប់ឆ្នាំ ១៩៩៤]"។

៥. ក្រុមមេធាវីការពារក្ដីទទួលស្គាល់ថា សំណៅឯកសារព្រះរាជប្រទានការលើកលែងទោស/ការ

---

អ.ប.ជ កថាខណ្ឌទី ១៨៥។ សំណៅបកប្រែនៃមាត្រា ១ (ដែលបានបកប្រែដោយអង្គភាពបកប្រែភាសា) មានខ្លឹមសារដូចខាងក្រោម៖

> អនុគ្រោះទោស អោយ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្ដន្ទាទោសប្រហារជីវិតបង់ និង រឹបអូស ទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង អនុគ្រោះទោសចំពោះការកាត់សេចក្ដីក្រោមច្បាប់ស្ដីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤...

[8] *សូមមើល* អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឧបសម្ព័ន្ធ។ សំណៅបកប្រែនៃមាត្រា ១ (ដែលបកប្រែដោយអង្គភាពបកប្រែភាសា) មានខ្លឹមសារដូចខាងក្រោម៖

> លើកលែងទោសឲ្យ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្ដន្ទាទោសប្រហារជីវិតបង់ និង រឹបអូស ទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ស្ដីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤...

[9] មានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងសំណៅបកប្រែនៅក្នុងផ្នែកបុព្វកថា និងនៅក្នុងមាត្រាដទៃទៀត ដែលចាំបាច់ត្រូវដោះស្រាយ។

[10] អង្គបុរេជំនុំជម្រះបកស្រាយចំណុចនេះថាជា "ការអនុគ្រោះទោសចំពោះការផ្ដន្ទាទោស"។ សាលដីកាលើការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌទី ៥៧ ដល់ទី ៥៩។

អនុគ្រោះទោសជាភាសាខ្មែរ គឺជាសំណៅឯកសារអាជ្ញាព្រឹត្តិ។ មានភាពមិនច្បាស់លាស់នៅក្នុងសំណៅឯកសារជាភាសាខ្មែរ។ ឧទាហរណ៍ ពាក្យ “លើកលែងទោស” ត្រូវបានបកស្រាយថា មានន័យ “ការអនុគ្រោះទោស” ផង និង “ការលើកលែងទោស”ផង[11]។ ការអនុវត្តការបកស្រាយ និងការបកប្រែជាក់លាក់ទាំងនេះ នឹងនាំឲ្យមានភាពមិនស្របគ្នា ឬលទ្ធផលមិនប្រក្រតី[12]។ ដើម្បីកំណត់ពីការបកស្រាយសមស្រប និងការបកប្រែជាភាសាអង់គ្លេសត្រឹមត្រូវចំពោះពាក្យនេះ វាគឺជាការចាំបាច់ ត្រូវពិចារណាទៅលើចេតនារបស់អ្នកចរចា និងអ្នកព្រាងអត្ថបទជាភាសាខ្មែរ[13]។ ទោះជាប្រើប្រាស់សំណៅបកប្រែមួយណាក៏ដោយ រាល់មន្ទិលសង្ស័យលើការបកស្រាយផ្នែកណាមួយនៃព្រះរាជក្រិត្យលើកលែងទោស និងអនុគ្រោះទោស ត្រូវតែដោះស្រាយដោយផ្តល់ប្រយោជន៍ឲ្យទៅ លោក អៀង សារី ដូចបានចែងដោយរដ្ឋធម្មនុញ្ញ[14]។

---

[11] អង្គបុរេជំនុំជម្រះបានសម្រេចថា ពាក្យ “លើកលែងទោស” អាចសំដៅលើការអនុគ្រោះទោសផង និង ការលើកលែងទោសផង។ *សូមមើល* សាលដីការបស់ អ.ប.ជ លើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៥៩។ រាជរដ្ឋាភិបាលកម្ពុជា និង អង្គភាពបកប្រែភាសា ក៏បកប្រែពាក្យនេះក្នុងន័យទាំងពីរនេះផងដែរ។

[12] អង្គបុរេជំនុំជម្រះធ្លាប់បានអះអាងថា ខ្លួននឹងប្រើប្រាសអត្ថន័យនៃពាក្យទាំងនេះទៅតាមន័យវេយ្យាករណ៍ និងន័យសាមញ្ញដែលប្រើ ប្រសិនបើមិនមានភាពមិនស្របគ្នា ឬលទ្ធផលមិនប្រក្រតីទេនោះ។ សាលដីការបស់ អ.ប.ជ កថាខណ្ឌទី ១៩៣។

[13] នៅក្នុងប្រទេសបារាំង ដែលភាគច្រើននៃប្រព័ន្ធច្បាប់ប្រទេសនេះត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ប្រព័ន្ធច្បាប់ប្រទេសកម្ពុជានោះ “នៅពេលដែលលិខិត[លក្ខន្តិកៈ] មានភាពច្បាស់លាស់ លិខិតនេះគួរត្រូវបានអនុវត្ត និងមិនត្រូវបានបកស្រាយឡើយ លុះត្រាណាមានលទ្ធផលមិនប្រក្រតី។ នៅពេលដែលលិខិតណាមួយមានភាពមិនច្បាស់លាស់ ឬ មានន័យច្រើនជាងមួយ [ឬបង្កើតឲ្យមានលទ្ធផលមិនប្រក្រតី] តុលាការមើលទៅលើចេតនានៃបញ្ញត្តិនោះ”។ ខ្លែ អឹម ជឺមែន (Claire M. Germain) *យុទ្ធសាស្ត្រក្នុងការបកស្រាយលក្ខន្តិកៈ និង ប្រវត្តិបញ្ញត្តិនៅក្នុងប្រទេសបារាំង* បោះពុម្ពដោយ 13 Duke J. Comp. & Int’l L. 195 ទំព័រទី ២០១ ដល់ ២០២ (ឆ្នាំ ២០០៣) (“*ជឺមែន៖ ការបកស្រាយលក្ខន្តិកៈ*”)។ ក្រុមមេធាវីការពារក្តីបានស្នើទៅអង្គជំនុំជម្រះសាលាដំបូង ឲ្យកោះហៅអ្នកព្រាង និងអ្នកចរចារស្នើសុំព្រះរាជប្រទានលើកលែងទោស និង អនុគ្រោះទោស ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចពីចេតនារបស់ពួកគាត់ តាមរយៈការផ្តល់សក្ខីកម្មផ្ទាល់មាត់ដោយធ្វើសម្បថ។ *សូមមើល* [redacted] ០៩ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E85។

[14] “វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ” រដ្ឋធម្មនុញ្ញ មាត្រា ៣៨។ ដូចដែរអង្គបុរេជំនុំជម្រះបានពន្យល់ នៅពេលបកស្រាយការលើកលែងទោស និង ការអនុគ្រោះទោសថា៖ “អង្គបុរេជំនុំជម្រះយល់ឃើញថា ចំពោះ “ទោស” នៅក្នុងប្រយោគទី២ នៃព្រះរាជក្រឹត្យ អាចត្រូវបានបកស្រាយថា ជនត្រូវចោទ “នឹងមិនអាចត្រូវតុលាការផ្តួចផ្តើមនីតិវិធីចោទប្រកាន់ចំពោះខ្លួនឡើយ” ដោយសារវាពាក់ព័ន្ធនឹងបញ្ហានៃការដាក់ទោស និង ការរំលោភបំពានលើ [ច្បាប់ឆ្នាំ ១៩៩៤]។ <u>អង្គបុរេជំនុំ</u>

៦. ពាក់ព័ន្ធទៅនឹងភាពខុសគ្នាទីមួយនោះ ការអនុវត្តឃ្លាបកប្រែ "ការអនុគ្រោះទោសលើការផ្តន្ទាទោស" នៅក្នុងបន្ទាត់ទីមួយនៃមាត្រា ១ នឹងនាំឲ្យមានភាពមិនស្របគ្នាទៅនឹងពាក្យក្នុងភាសាខ្មែរ ដែលជា "ការលើកលែងទោស" ដែលមានន័យថា "លើកលែងទោស"។ ពាក្យ "ទោស" នៅក្នុងន័យដើមរបស់ពាក្យនេះ មានន័យលើសពីពាក្យ "ផ្តន្ទាទោស"។ ការផ្តន្ទាទោសណាមួយអាចត្រូវបានលើកលែង ដោយមិនមានការប៉ះពាល់ដល់ការសម្រេចថាមានទោស ឬពិរុទ្ធភាព។ ពាក្យ "លើកលែងទោស" គួរតែជាពាក្យដែលត្រូវយកមកប្រើ ដោយហេតុថាពាក្យនេះអាចឲ្យគេយល់បានទូលំទូលាយជាងពាក្យថា "ការអនុគ្រោះទោស"។

៧. ពាក់ព័ន្ធទៅនឹងភាពខុសគ្នាទីពីរវិញ ការប្រើឃ្លាបកប្រែ "ការលើកលែងទោស... ចំពោះការផ្តន្ទាទោសដែលមានចែង" នៅក្នុងច្បាប់ឆ្នាំ ១៩៩៤ ជាជាងការប្រើឃ្លា "ការអនុគ្រោះទោសចំពោះការកាត់សេចក្តីក្រោមច្បាប់ឆ្នាំ ១៩៩៤" នឹងនាំឲ្យមានលទ្ធផលមិនសមហេតុផលមួយ។ វានឹងមិនមានលក្ខណៈសមហេតុផលទេក្នុងបកស្រាយមាត្រា១ ថាផ្តល់ឲ្យនូវការលើកលែងទោសសម្រាប់ការផ្តន្ទាទោសណាមួយដែលមានចែងនៅក្នុងច្បាប់ឆ្នាំ ១៩៩៤ នោះទេ ពីព្រោះការធ្វើបែបនេះនឹងតម្រូវឲ្យមានការកាត់សេចក្តីមួយ និងមានការផ្តន្ទាទោស មុននឹងមាត្រានេះមានអានុភាព។

៨. ដោយសារតែមានសំណៅបកប្រែផ្សេងគ្នា ដែលធ្វើឲ្យមានលទ្ធផលមិនសមហេតុផល និងការប្រើមិនស្របគ្នាដោយសារតែការអនុវត្តការបកប្រែជាក់លាក់ណាមួយនោះ គេត្រូវតែពិចារណាទៅលើចេតនារបស់អ្នកចរចា និងអ្នកព្រាងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស។ ក្រុមមេធាវីការពារក្តីបានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូងនូវសេចក្តីថ្លែងការណ៍របស់ លោក អៀង សារី ដែលពន្យល់អំពីការយល់ដឹងរបស់គាត់អំពីចេតនារបស់ខ្លួនគាត់ផ្ទាល់ និងចេតនារបស់អ្នកព្រាង[15]។ វាគឺជាការមិនសមហេតុផលទេដែលលើកឡើងថា លោក អៀង សារី មានចេតនាសុំការលើកលែងទោសចំពោះការផ្តន្ទាទោសរបស់គាត់ ប្រសិនបើគាត់នៅតែអាចត្រូវបានចោទប្រកាន់សារជាថ្មីចំពោះអំពើដដែលនោះ។ វាក៏ជាការមិនសមហេតុផលផងដែរដែលលើកឡើងថា គាត់មានចេតនាឲ្យគេកាត់សេចក្តីលើរូបគាត់ជាលើកទីពីរ មុនពេលគាត់អាចទទួលបាននូវប្រយោជន៍

---

ជម្រះនឹងលើកបញ្ហានេះឡើង តាមទិដ្ឋភាពនេះ ដោយសារតែការពន្យល់នេះគឺផ្តល់ផលប្រយោជន៍ល្អបំផុតចំពោះជនត្រូវចោទ។" សាលដីការបស់ អ.ប.ជ លើការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៥៩ (គូសបញ្ជាក់បន្ថែម)។

[15] សំបុត្រភស្តុតាងរបស់លោក អៀង សារី ទាក់ទងនឹងវិសាលភាព ចេតនានៅពីក្រោយ និងសារតានៃព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ E84 ឧបសម្ព័ន្ធ "ក" ("សំបុត្រភស្តុតាងរបស់ លោក អៀង សារី")។

ពីការអនុគ្រោះទោស ដែលបានផ្តល់ឲ្យនៅក្នុងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនោះ។

## ខ. ព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោស ស្របទៅនឹងរដ្ឋធម្មនុញ្ញ

### ១. ព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោស ត្រូវបានផ្តល់ឲ្យស្របទៅនឹងរដ្ឋធម្មនុញ្ញ

៩. ក្រុមមេធាវីការពារក្តីស្នើពីដំបូងដោយគោរពថា អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការក្នុងការពិចារណាថាតើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ស្របទៅនឹងរដ្ឋធម្មនុញ្ញដែរឬទេ គឺថាតើព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះមានសុពលភាពឬទេនោះ។ សុពលភាពរបស់ច្បាប់នានាដែលប្រកាស់ឲ្យប្រើដោយព្រះមហាក្សត្រអាចត្រូវបានពិនិត្យពីធម្មនុញ្ញភាពដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ[16]។ ព្រះរាជកិច្ចផ្សេងៗទៀតរបស់ព្រះមហាក្សត្រ មិនអាចត្រូវបានជំទាស់តវ៉ាដោយស្ថាប័នរដ្ឋបានឡើយ។ ចំណុចនេះមានចែងនៅក្នុងមាត្រា ៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថា ព្រះមហាក្សត្រមិនអាចបំពានបានឡើយ។ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតតុលាការ អនុញ្ញាតឲ្យ អ.វ.ត.ក សម្រេចលើវិសាលភាពនៃការអនុគ្រោះទោស ប៉ុន្តែលិខិតុបករណ៍ទាំងនេះមិនបានចែងពីយុត្តាធិការរបស់ អ.វ.ត.ក ក្នុងការសម្រេចលើសុពលភាព[17] នោះទេ។ យ៉ាងណាក៏ដោយ ដោយហេតុថាក្រុមមេធាវីការពារក្តីត្រូវបានអង្គជំនុំជម្រះសាលាដំបូង អញ្ជើញអោយលើកពីបញ្ហានេះ ក្រុមមេធាវីការពារក្តីនឹងលើកឡើងពីបញ្ហានេះនៅក្នុងកថាខណ្ឌខាងក្រោមទាំងនេះ។

១០. មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញមិនដាក់កំហិតលើអំណាចរបស់ព្រះមហាក្សត្រក្នុងការផ្តល់ឲ្យនូវការអនុគ្រោះទោស ឬ ការលើកលែងទោសនោះទេ។ មាត្រានេះក៏មិនដាក់កំហិតលើវិសាលភាពនៃការអនុគ្រោះទោស ឬការលើកលែងទោសដែលបានផ្តល់ឲ្យនោះដែរ។ មាត្រានេះចែងយ៉ាងសាមញ្ញថា "ព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស"។ មាត្រា ៩០ (និងមាត្រា

---

[16] សូមមើល រដ្ឋធម្មនុញ្ញ មាត្រា ១៣៦ ថ្មី ដល់ ១៤៤ ថ្មី។

[17] សូមមើល កិច្ចព្រមព្រៀង មាត្រា ១១(២) "អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាយល់ព្រមថា វិសាលភាពនៃការលើកលែងទោសគឺជាបញ្ហាដែលត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ", ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤០ ថ្មី "វិសាលភាពនៃការអនុគ្រោះទោស ឬ ការលើកលែងទោស ដែលអាចបានផ្តល់ឲ្យ មុននឹងមានច្បាប់នេះ គឺជាបញ្ហាដែលនឹងត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"។

៩០ ថ្មី) នៃរដ្ឋធម្មនុញ្ញចែងថា “រដ្ឋសភាជាតិត្រូវអនុម័តច្បាប់លើការអនុគ្រោះទោសទូទៅ”[18]។ ព្រះមហាក្សត្របានផ្ដល់ការអនុគ្រោះ[19] ហើយរដ្ឋសភាជាតិបានអនុម័តព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ដោយមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល[20]។ ហេតុដូច្នេះ ព្រះរាជប្រទានលើកលែងទោស និងអនុគ្រោះទោស ត្រូវបានផ្ដល់ឱ្យដោយមានសុពលភាពស្របតាមរដ្ឋធម្មនុញ្ញ។

---

[18] ពាក្យជាភាសាខ្មែរ ដែលប្រើនៅក្នុងមាត្រា ២៧ និង មាត្រា ៩០ ថ្មី គឺ “លើកលែងទោស” ដែលអាចសំដៅទៅលើ ការអនុគ្រោះទោសផង និង ការលើកលែងទោសផង ដូចបានភាក្សាពីខាងលើ។ អង្គបុរេជំនុំជម្រះបានសម្រេចថា ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស មានអត្ថន័យទាំងពីរនេះ។ *សូមមើល* សាលដីការបស់ អ.ប.ជ លើការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ ៥៩។

[19] ព្រះមហាក្សត្របានចេញការលើកលែងទោស និង អនុគ្រោះទោស ជាព្រះរាជក្រឹត្យ ដែលលើកឡើងថា ព្រះរាជក្រឹត្យនេះនឹងមានអានុភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខានោះតទៅ ហើយព្រះរាជក្រឹត្យនេះត្រូវអនុវត្តឱ្យបានពេញលេញដោយក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌។ ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស មាត្រា ២ និង មាត្រា ៣។ ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោសត្រូវបានឡាយព្រះហស្ថលេខាដោយព្រះមហាក្សត្រនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦ ហើយចាប់ពីថ្ងៃនោះមក បានក្លាយទៅជាច្បាប់ដែលមានសុពលភាព។ ព្រះមហាក្សត្រមិនដែលបានបញ្ជាក់ថា ព្រះអង្គ ទ្រង់ បានអនុវត្តហួសព្រះរាជអំណាចធម្មនុញ្ញរបស់ទ្រង់ ក្នុងការផ្ដល់ឱ្យនូវការអនុគ្រោះទោសនេះទេ។ ប្រសិនបើព្រះអង្គ ទ្រង់មានជំនឿថា ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោសមិនមានសុពលភាពនោះ ទ្រង់មានឱកាសដើម្បីបញ្ជាក់បំភ្លឺពីបញ្ហានេះ នៅពេលដែលទ្រង់ត្រូវបានស្នើឱ្យចូលរួមនៅក្នុងកិច្ចស៊ើបសួររបស់ ក.ស.ច.ស ដែលឱកាសនេះ ត្រូវបានព្រះអង្គ ទ្រង់ បដិសេធ។ *សូមមើល* លិខិតរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel LEMONDE ផ្ញើរជូនសម្ដេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដែលស្នើឱ្យមានការស្ដាប់យកព្រះរាជចម្លើយព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ព្រះវររាជបិតា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឋានៈជាសាក្សី ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារលេខ D122/5។ សាលដីកាលើកទីពីរលើបណ្ដឹងឧទ្ធរណ៍របស់ លោក អៀង សារី និង លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D314/1/12។

[20] ការបញ្ជាក់បំភ្លឺពី ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ ព្រះវររាជបិតា ព្រះមហាក្សត្រកម្ពុជា ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៦។ *សូមមើលផងដែរនូវ* អត្ថបទ *ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ លើកលែងទោសឱ្យ លោក អៀង សារី* ចេញផ្សាយក្នុងសារព័ត៌មាន បាងកក ប៉ុស្តិ៍ (Bangkok Post) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៦ “ព្រះករុណាព្រះបាទសម្ដេចព្រះមហាក្សត្រ បានឡាយព្រះហស្ថលេខាផ្ដល់ការអនុគ្រោះទោស... ដោយមានការគាំទ្រពីមតិពីរភាគបី (នៃសមាជិកទាំងអស់) របស់រដ្ឋសភា” សម្ដេច ហ៊ុន សែន ដែលកាលនោះជានាយករដ្ឋមន្ត្រីទីពីរ ប្រាប់ទៅសារព័ត៌មាន រ៉ោយទ័រ (Reuters)... ដោយមានប្រសាសន៍ថា វាមានភាពងាយស្រួលក្នុងប្រមូលយកហត្ថលេខាពីសមាជិកសភានៅក្នុងរដ្ឋសភាជាតិដែលមានសមាជិកសរុបចំនួន១២០នាក់ ដោយសារថាគាត់ និង ព្រះអម្ចាស់ នរោត្តម រណឫទ្ធិ ដែលកាលនោះជានាយករដ្ឋមន្ត្រីទីមួយ គឺជាមេដឹកនាំនៃបក្សធំៗទាំងពីរ។”

១១. ច្បាប់ឆ្នាំ ១៩៩៤ ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិ បង្ហាញថា រដ្ឋសភាជាតិទទួលស្គាល់នូវព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រ ក្នុងការផ្តល់ការអនុគ្រោះទោសឲ្យទៅពួកខ្មែរក្រហមដែលធ្វើសមាហរណកម្ម។ មាត្រា ៧ នៃច្បាប់ឆ្នាំ ១៩៩៤ ចែងថា "ព្រះមហាក្សត្រ ទ្រង់អាចបន្ធូរបន្ថយទោស ឬ លើកលែងទោស តាមព្រះរាជសិទ្ធិដែលមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ"។

១២. រដ្ឋសភាជាតិបានអនុម័តច្បាប់មួយដែលផ្តល់ឲ្យនូវអភ័យឯកសិទ្ធិដាច់ខាត[21] ដល់ទៅជនទាំងឡាយណាដែលអាចត្រូវបានចោទថាពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានកើតឡើងនៅក្នុងអំឡុងរបបខ្មែរក្រហម។ ជាអាទិ នៅក្នុងឆ្នាំ ២០០៤ រដ្ឋសភាជាតិបានអនុម័តច្បាប់មួយ[22] ដែលផ្តល់ឲ្យព្រះវរបិតាព្រះមហាក្សត្រ នរោត្តម សីហនុ នូវអភ័យឯកសិទ្ធិអស់មួយជីវិត[23]។ ចំណុចនេះបញ្ជាក់បន្ថែមថា រដ្ឋសភាជាតិចាត់ទុកច្បាប់បែបនេះថាមានសុពលភាព ហើយតាមដែលក្រុមមេធាវីការពារក្តីបានដឹង ជាពិសេសដោយសារតែមិនមានការជំទាស់តវ៉ាតាមផ្លូវរដ្ឋធម្មនុញ្ញណាមួយដោយសារការអនុម័តលើច្បាប់នេះឡើយ។

## ២. រដ្ឋធម្មនុញ្ញមិនដាក់កំហិតលើប្រភេទឧក្រិដ្ឋកម្មដែលអាចត្រូវបានអនុគ្រោះទោស ឬលើកលែងទោសឡើយ

១៣. មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញដែលបង្ហាញយ៉ាងច្បាស់ពីការដាក់កំហិតណាមួយលើប្រភេទឧក្រិដ្ឋកម្មដែលអាចត្រូវបានអនុគ្រោះទោស ឬលើកលែងទោស ដោយអនុលោមតាមមាត្រា ២៧ និង មាត្រា ៩០ ថ្មី ឡើយ។ មិនមានបទប្បញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញ អាច

---

[21] អភ័យឯកសិទ្ធិ ត្រូវបានកំណត់និយមន័យថាជា "ការលើកលែងទៅតាមតួនាទី ឲ្យរួចផុតពីការទទួលខុសត្រូវ ឬ ពីសេវាកម្មដំណើរការ ជាពិសេស ការលើកលែងនេះ ត្រូវបានផ្តល់ឲ្យទៅមន្ត្រីសាធារណៈ" វចនានុក្រម Black's Law 752 (កំណែលើកទី៧ ឆ្នាំ ១៩៩៩)។

[22] ច្បាប់ស្តីពីការរៀបចំព្រះបរមងារ និងព្រះរាជបុព្វសិទ្ធិថ្វាយដល់អតីតព្រះមហាក្សត្រ និងព្រះរាជមហេសី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៤។ មាត្រា៧ចែងថា៖ "ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ... និង សម្តេចព្រះរាជអគ្គមហេសី មុនិនាថ សីហនុ ... ត្រូវបានរក្សាព្រះរាជបុព្វសិទ្ធិ អភ័យឯកសិទ្ធិ ពេញលេញ និងមិនអាចរំលោភបំពានបានឡើយ ដូចពេលដែលព្រះអង្គគង់នៅគ្រងរាជសម្បត្តិ"។

[23] ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ត្រូវបានភ្ជាប់ទំនាក់ទំនងទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិនៅក្នុងអំឡុងឆ្នាំ ១៩៥០ និង ឆ្នាំ ១៩៦០ ក៏ដូចជាក្នុងសម័យខ្មែរក្រហមផងដែរ។ *សូមមើលឯកសាររបស់* ដេវីត ឆែនលើ (David Chandler) ស្តីពី សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា ទំព័រទី ១១២ ដល់ ១១៣, ទំព័រទី ១២៩ ដល់ ១៣០, ទំព័រទី ១៣៣ ដល់ ១៣៤, និង ទំព័រទី ១៨៣ និង ២៤៤ (កំណែលើកទី ៤)។

ត្រូវបានពិចារណាដោយប្រយោលថា ដាក់កំហិតលើប្រភេទឧក្រិដ្ឋកម្មដែលអាចត្រូវបានអនុគ្រោះទោស អនុលោមតាមមាត្រា ២៧ និង មាត្រា ៩០ ថ្មី នោះដែរ។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញតម្រូវឱ្យប្រទេសកម្ពុជា "ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"[24]។ មាត្រាមួយនេះ ដែលមិនយោងទៅលើការអនុគ្រោះទោសផងនោះ មិនអាចជាមាត្រាជាក់លាក់គ្រប់គ្រាន់ សម្រាប់ឱ្យចាត់ទុកថាជាការកំហិតមកលើមាត្រា ២៧ ឬ មាត្រា ៩០ ថ្មីឡើយ[25]។

១៤. អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ប្រទេសកម្ពុជាដែលបានផ្តល់សច្ចាប័នដល់ [កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ] ក៏ធ្លាប់មាន និង បន្តមានកាតព្វកិច្ចក្នុងការធានាថាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យគឺសំដៅដល់ការបង្កនូវការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ត្រូវទទួលបាននូវការជួសជុលប្រកបដោយប្រសិទ្ធភាព"[26]។ ចំណុចនេះអាចជាការពិត ប៉ុន្តែមិនអាចមានន័យថា ព្រះមហាក្សត្រមិនមានអំណាចតាមរដ្ឋធម្មនុញ្ញដើម្បីផ្តល់ឱ្យនូវព្រះរាជប្រទានលើកលែងទោស និងអនុគ្រោះទោសឡើយ។ រដ្ឋមួយមាន និងត្រូវមានឆន្ទានុសិទ្ធិក្នុងការកំណត់ថាតើខ្លួនអាចផ្តល់ការជួសជុលដ៏មានប្រសិទ្ធភាព មួយដល់ជនរងគ្រោះបានដោយរបៀបណា។ ការជួសជុលដ៏មានប្រសិទ្ធភាពមួយមិនចាំបាច់ត្រូវ តែជាការកាត់សេចក្តីនោះទេ។ បើទោះជាបែបនេះក៏ដោយ ជនរងគ្រោះនៃក្រុមកម្ពុជាប្រជាធិបតេយ្យ មិនត្រូវបានរារាំងពីការទទួលបាននូវការជួសជុលបែបនេះឡើយ។ ព្រះរាជប្រទានលើកលែងទោស និងអនុគ្រោះទោស គ្រាន់តែការពារ លោក អៀង សារី ពីការកាត់សេចក្តីតែ

---

[24] នៅក្នុងឆ្នាំ ១៩៩៦ (ក៏ដូចនាពេលបច្ចុប្បន្នផងដែរ) នៅពេលដែលការលើកលែងទោស និង ការអនុគ្រោះទោសត្រូវបានផ្តល់ឱ្យលោក អៀង សារី មិនមានចំណុចណាមួយនៅក្នុងលិខិតុបករណ៍ទាំងនេះ ដែលនឹងរារាំងដល់ការផ្តល់ឱ្យនូវការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិនោះទេ ដោយសារតែគ្មានតួនាទីច្បាស់លាស់ណាមួយ ដែលតម្រូវឱ្យធ្វើការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិសំខាន់ៗឡើយ។ *សូមមើល ខាងក្រោម* កថាខណ្ឌ ២០ ដល់ ២៣។

[25] គោលការណ៍នៃការបកស្រាយលក្ខន្តិកៈ ត្រូវបានគេស្គាល់ថាជា *Generalia specialibus non derogant* ដែលអាចបកប្រែថា "អ្វីដែលជាទូទៅមិនរារាំង (ឬធ្វើឱ្យអន់ថយ) ដល់អ្វីដែលជាក់លាក់នោះទេ" វចនានុក្រម Black's Law ទំព័រ ១៦៣៩ (កំណែលើកទី ៧ ឆ្នាំ ១៩៩៩)។

[26] សាលដីការបស់ អ.ប.ជ កថាខណ្ឌទី ២០១ *ដោយដកស្រង់* ICCPR មាត្រា ២(៣)(ក) ដូចតទៅ៖ "រដ្ឋភាគីនៃកតិកាសញ្ញានេះសន្យា ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និង សេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ"។

ប៉ុណ្ណោះ។ ការកាត់សេចក្តីលើមេដឹកនាំខ្មែរក្រហមដទៃទៀត នៅតែអាចធ្វើទៅបាន។

១៥. ការអនុគ្រោះទោស គឺជាឧបករណ៍ដ៏សំខាន់មួយដែលរដ្ឋនានាអាចប្រើប្រាស់ដើម្បីលើកតម្កើងសន្តិភាព។ សារប្រយោជន៍នៃឧបករណ៍នេះត្រូវបានអ្នកប្រាជ្ញជាច្រើនបានលើកឡើង[27]។ ជាអាទិ៍ លោក សាស្ត្រាចារ្យ វីលៀម ស្កាបាស (William Schabas) បានអះអាងថា "សន្តិភាព និង ការផ្សះផ្សា គឺជាតម្លៃស្របច្បាប់ដែលគួរតែមានវត្តមាននៅក្នុងច្បាប់ស្តីពីសិទ្ធិមនុស្ស។ កត្តាទាំងពីរនេះចាំបាច់ត្រូវថ្លឹងថ្លែងជាមួយនឹងសារៈសំខាន់នៃការកាត់សេចក្តី ជាជាងការលុបចោលយ៉ាងសាមញ្ញនូវកត្តាទាំងពីរនេះ"[28]។

### ៣. ក្នុងនាមជាតុលាការជាតិពិចារណាលើការអនុគ្រោះទោស និងការលើកលែងទោសថ្នាក់ជាតិ កាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាមិនជះឥទ្ធិពលលើសុពលភាពរបស់ព្រះរាជទានលើកលែងទោស និងអនុគ្រោះទោសឡើយ

១៦. អ.វ.ត.ក គឺជាតុលាការកម្ពុជាដែលជាប់កាតព្វកិច្ចដោយច្បាប់កម្ពុជា[29]។ សុពលភាពនៃការអនុគ្រោះទោសថ្នាក់ជាតិ នៅក្នុងរដ្ឋដែលបានផ្តល់ការអនុគ្រោះទោសនោះ គឺជាបញ្ហាច្បាប់ជាតិរបស់រដ្ឋនោះសុទ្ធសាធ[30]។ កាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ដែលជារដ្ឋអធិបតេយ្យមួយនោះ

---

[27] *សូមមើល ជាឧទាហរណ៍* ឯកសាររបស់ វីលៀម ហ្សាបាស ស្តីពី *ការអនុគ្រោះទោស, គណៈកម្មការផ្សះផ្សា និងរកការពិតនៅប្រទេស សេរ៉ា ឡេអូន, និង តុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន* លេខ ១១ បោះពុម្ពដោយ U. C. Davis J. Int'l L. & Pol'Y,ទំព័រទី ១៤៥, និងទី ១៦៣ ដល់ ១៦៨ (ឆ្នាំ ២០០៤)។ ឯកសាររបស់ ឆាលស៍ ភី ត្រាំប៊ូល ទីបួន (Charles P. Trumbull IV) ស្តីពី *ផ្តល់ការអនុគ្រោះទោសជាឱកាសលើកទីពីរ* លេខ ២៥ បោះពុម្ពដោយ Berkeley J. Int'l L. ទំព័រ ២៨៣ និង ៣១៤ (ឆ្នាំ ២០០៨)។ ឯកសាររបស់ លូអីស ម៉ែល្លីឌឺ (Louise Mallinder) ស្តីពី *សេចក្តីណែនាំស្តីពី ការជួសជុលសំណង, ការអនុគ្រោះទោស, ការលើកលែងទោស និង ការចោទប្រកាន់ នៅអាហ្វ្រិកខាងត្បូង* ឯកសារការងារ លេខ ២ ដកចេញពីសៀវភៅ *ហួសពីនីត្យានុកូលភាព៖ ការអនុគ្រោះទោស អន្តរកាល និង ការប្រែប្រួលនៃជម្លោះ* ទំព័រ ៧០ (ខែ កុម្ភៈ ឆ្នាំ ២០០៩)។

[28] ឯកសាររបស់ ហ្សាបាស ស្តីពី *គណៈកម្មការផ្សះផ្សា និងរកការពិតនៅប្រទេស សេរ៉ា ឡេអូន, និង តុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន* ត្រង់ទំព័រទី ១៦៥ ដល់ ១៦៨។

[29] សម្រាប់សារណាបន្ថែមលើបញ្ហានេះ សូមមើលសារណាបន្ថែមនានាផ្សេងទៀត ដែលក្រុមមេធាវីការពារក្តី មានបំណងលើកឡើងពីបញ្ហានេះនៅក្នុងសារណាបន្ថែមរបស់ខ្លួនលើភាពអាចអនុវត្តបាននូវច្បាប់អន្តរជាតិ។

[30] ដូចដែលអង្គជំនុំជម្រះជាន់ខ្ពស់របស់តុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន បានពន្យល់ថា "ការផ្តល់ឱ្យនូវការអនុគ្រោះទោសឬការលើកលែងទោស ដោយមិនមានវិមតិសង្ស័យ គឺជាការអនុវត្តរបស់រដ្ឋអំណាចអធិបតេយ្យ ដែលត្រូវបានភ្ជាប់ទំនាក់ទំនងជាចាំបាច់ ទៅនឹងយុត្តាធិការព្រហ្មទណ្ឌរបស់រដ្ឋដែលអនុវត្តអំណាចអធិបតេយ្យបែបនេះ ឱ្យតែពាក់ព័ន្ធ

មិនពាក់ព័ន្ធជាមួយនឹងការសម្រេចលើសុពលភាពរបស់ព្រះរាជប្រទានលើកលែងទោស និងការអនុគ្រោះទោសនៅក្នុងតុលាការកម្ពុជាឡើយ[31]។

១៧. អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម និងអនុសញ្ញាទីក្រុងហ្សឺណែវ សុទ្ធតែដាក់កាតព្វកិច្ចឲ្យរដ្ឋជាហត្ថលេខីនានាអនុវត្តច្បាប់ជាតិរបស់ខ្លួនដើម្បីដាក់ទណ្ឌកម្មដល់បុគ្គលទាំងឡាយណា ដែលបានប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានកំណត់ជាក់លាក់នៅក្នុងអនុសញ្ញាទាំងនេះ[32]។ ប្រទេសកម្ពុជាបានអនុវត្តកាតព្វកិច្ចនេះ ដោយក្លាយជាភាគីមួយនៃអនុសញ្ញាទាំងនេះ។ ប៉ុន្តែ គេត្រូវធ្វើការបែងចែករវាងកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាដែលត្រូវធ្វើចំពោះប្រជាជនរបស់ខ្លួន។ កាតព្វកិច្ចទាំងពីរនេះគឺជារបបច្បាប់ពីរដាច់ដោយឡែកពីគ្នា។ ប្រសិនបើប្រទេសកម្ពុជាមិនបានបំពេញកាតព្វកិច្ចអន្តរជាតិរបស់ខ្លួនឲ្យបានពេញលេញ នេះគឺជាបញ្ហារវាងប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ[33]។ បញ្ហានេះមិនប៉ះពាល់ដល់សិទ្ធិ ឬកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះប្រជាជនរបស់ខ្លួនឡើយ។ នៅក្នុងរបបច្បាប់ជាតិ ព្រះរាជប្រទានលើកលែងទោស និងអនុគ្រោះទោសឲ្យ លោក អៀង សារី មានសុពលភាព និងមិនអាចត្រូវបានធ្វើមោឃភាពដោយកាតព្វកិច្ចអន្តរជាតិណាមួយរបស់ប្រទេស

---

ទៅនឹងឧក្រិដ្ឋកម្មណាមួយ” *រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង កាឡុន (Kallon)* ឯកសារលេខ SCSL-04-15-AR72(E) *និង កាម៉ារ៉ា (Kamara)* ឯកសារលេខ SCSL-04-16-AR72(E) សាលដីកាលើការជំទាស់តវ៉ាលើយុត្តាធិការ៖ ការអនុគ្រោះទោសចំពោះ Lome Accord ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៤ (“សាលដីកាលើ Lome Accord”) កថាខណ្ឌទី ៦៧។

[31] ចំណុចនេះមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៤៥ មាត្រា ២(៧)៖

> <u>មិនមានអ្វីនៅក្នុងធម្មនុញ្ញនេះ អនុញ្ញាតឲ្យអង្គការសហប្រជាជាតិដើម្បីធ្វើអន្តរាគមន៍នៅក្នុងបញ្ហានានា ដែលស្ថិតនៅក្រោមយុត្តាធិការជាតិរបស់រដ្ឋភាគីណាមួយ ជាចាំបាច់នោះទេ</u> ឬ តម្រូវឲ្យសមាជិកយកបញ្ហាបែបទាំងនេះមកដោះស្រាយក្រោមធម្មនុញ្ញបច្ចុប្បន្នមួយនេះឡើយ។ ប៉ុន្តែ គោលការណ៍នេះមិនត្រូវជាភាពលម្អៀងសម្រាប់ការអនុវត្តនូវវិធានការនានា នៅក្នុង គន្ថី ៧។ (គូសបញ្ជាក់បន្ថែម)

[32] អនុសញ្ញាទីក្រុងហ្សឺណែវមួយ មាត្រា ៤៩, អនុសញ្ញាទីក្រុងហ្សឺណែវពីរ មាត្រា ៥០, អនុសញ្ញាទីក្រុងហ្សឺណែវបី មាត្រា ១២៩ និង អនុសញ្ញាទីក្រុងហ្សឺណែបួន មាត្រា ១៤៦, អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា ៥, អនុសញ្ញាប្រឆាំងអំពើទារុណកម្ម មាត្រា ៤។

[33] ចំណាត់ការសមស្របសម្រាប់ករណីនេះគឺថា រដ្ឋណាមួយប្តឹងប្រទេសកម្ពុជានៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ។ ករណីបែបនេះត្រូវតែប្តឹងប្រឆាំងនឹងប្រទេសកម្ពុជា ក្នុងនាមប្រទេសនេះគឺជាសមាជិកមួយនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដោយរដ្ឋភាគីមួយទៀត។ *សូមមើល* អនុសញ្ញាស្តីពីការការពារ និង ដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសាន៍ ដែលបានអនុម័តដោយសេចក្តីសម្រេចលេខ ២៦០ (III) ក របស់អង្គការសហប្រជាជាតិ។ មហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ ចូលជាធរមាន នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៥១ មាត្រា ៩។

កម្ពុជាឡើយ។ ឋានៈអាជ្ញាបញ្ញោ (*jus cogens*) នៃឧក្រិដ្ឋកម្មអន្តរជាតិមិនកែប្រែទៅលើការវិភាគនេះឡើយ[34]។ យុត្តាធិការជាតិមានសមត្ថកិច្ចក្នុងការផ្តល់ឱ្យនូវការអនុគ្រោះ និងការលើកលែងទោសចំពោះឧក្រិដ្ឋកម្មដែលមានឋានៈអាជ្ញាបញ្ញោ។ ការផ្តល់ការអនុគ្រោះទោស ឬការលើកលែងទោសបែបនេះ គឺជាបញ្ហាអធិបតេយ្យជាតិ និងជាបញ្ហាច្បាប់ជាតិ[35]។

១៨. អង្គបុរេជំនុំជម្រះបានអះអាងថា ការអនុគ្រោះទោសចំពោះគ្រប់បទឧក្រិដ្ឋដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ នឹងមិនស្របទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ក្នុងការកាត់សេចក្តី និងផ្តន្ទាទោសដល់ជនដែលប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។ អង្គបុរេជំនុំជម្រះ<u>មិន</u>បានយល់ថា ភាពមិនស្របគ្នាទៅនឹងការគោរពកាតព្វកិច្ចអន្តរជាតិ នឹងធ្វើឱ្យការអនុគ្រោះទោសអស់សុពលភាពនោះទេ។ អង្គបុរេជំនុំជម្រះគ្រាន់តែយល់ឃើញថា ព្រះមហាក្សត្រនឹងមិនមានព្រះរាជបំណងបង្កើតឱ្យមានភាពមិនស្របគ្នាជាមួយនឹងកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជាឡើយ[36]។ កំហុសនៃការវិភាគនេះត្រូវបានដោះស្រាយនៅក្នុងផ្នែកខាងក្រោមដែលពាក់ព័ន្ធទៅនឹងសាលដីការបស់ អ.ប.ជ។

---

[34] ក្រៅពីបញ្ហានៃការគោរពទៅតាមកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ក.ស.ព ធ្លាប់លើកជាទឡ្ហីករណ៍រួចហើយថា ច្បាប់បង្កើត អ.វ.ត.ក តម្រូវឱ្យ អ.វ.ត.ក ពិចារណាទៅលើ “បទដ្ឋានអន្តរជាតិ” ជាក់លាក់មួយចំនួន ដែល ក.ស.ព អះអាងថា នឹងតម្រូវមិនឱ្យអនុវត្តព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោសចំពោះបទឧក្រិដ្ឋអាជ្ញាបញ្ញោបានទេ។ សម្រាប់ការពិភាក្សាលើកំហុសនៃទឡ្ហីករណ៍មួយនេះ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី កថាខណ្ឌ ទី៧១ ដល់ ទី៧២។

[35] ជាអាទិ៍ កិច្ចព្រមព្រៀង អាប៊ីដចាន (Abidjan) គឺជាកិច្ចព្រមព្រៀងមួយដែលត្រូវបានផ្តល់ឱ្យ នៅក្នុងយុត្តាធិការជាតិរបស់ប្រទេស សេរ៉ា ឡេអូន ដែលបានផ្តល់ឱ្យនូវការអនុគ្រោះទោសទូទៅសម្រាប់រាល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិដោយ រណសិរ្សរួបរួមបដិវត្តន៍ សេរ៉ា ឡេអូន។ ការចរចារស្នើសុំ ដែលនាំឱ្យមានកិច្ចព្រមព្រៀងមួយនេះ ត្រូវបានជួយសម្រួលដោយ បេសកជនពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់ប្រទេស សេរ៉ា ឡេអូន ដែលរួមជាមួយនឹងអ្នកតំណាងផ្សេងៗទៀតនៃអង្គការបង្រួបបង្រួមអាហ្វ្រិក និង Commonweath បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះឱ្យធ្វើជាអ្នកធានាខាងផ្លូវចិត្ត។ សហគមន៍អន្តរជាតិបានទទួលស្គាល់នាពេលនោះថា រដ្ឋាភិបាលប្រទេសសេរ៉ា ឡេអូន មានសមត្ថកិច្ចក្នុងការផ្តល់ឱ្យនូវការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មដែលគេអះអាងថាមានលក្ខណៈអាជ្ញាបញ្ញោ។ *សូមមើល* ឯកសារស្តីពី បេសកម្មរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេស សេរ៉ា ឡេអូន តាមរយៈគេហទំព័រ http://www.un.org/en/peacekeeping/missions/past/unamsil/background.html ត្រង់ផ្នែកសាវតា។ កិច្ចព្រមព្រៀងសន្តិភាព អាប៊ីដចាន រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសេរ៉ា ឡេអូន និង រណសិរ្សបង្រួបបង្រួមបដិវត្តន៍សេរ៉ា ឡេអូន ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ មាត្រា ២៨៖ “រដ្ឋាភិបាលប្រទេស កូត ឌីវ័រ (Cote d’Ivoire), អង្គការសហព្រះជាជាតិ, អង្គការបង្រួបបង្រួមអាហ្វ្រិក និង ប្រទេស Commonwealth ត្រូវដើរតួរអ្នកធានាថា កិច្ចព្រមព្រៀងសន្តិភាពនេះត្រូវបានអនុវត្ត ដោយសុច្ចរឹត និងដោយសេចក្តីសច្ចៈ ដោយភាគីទាំងពីរ”។

[36] *ដូចលេខជើងទំព័រខាងលើ។*

## ៤. បើទោះជា អ.វ.ត.ក ត្រូវចាត់ទុកតុលាការដែលមានលក្ខណៈអន្តរជាតិក៏ដោយ ក៏ព្រះរាជទានលើកលែងទោស និង អនុគ្រោះទោសនៅតែមានសុពលភាព

១៩. អង្គបុរេជំនុំជម្រះយល់ឃើញថា អ.វ.ត.ក គឺជា "តុលាការដែលមានលក្ខណៈអន្តរជាតិ"[37]។ បើទោះជា អ.វ.ត.ក អាចត្រូវបានចាត់ទុកថា "មានលក្ខណៈអន្តរជាតិ"[38] ដោយសារតែជំនួយបច្ចេកទេសអន្តរជាតិដែលតុលាការនេះទទួលបាន ក៏លក្ខណៈនេះមិនធ្វើឲ្យ អ.វ.ត.ក ទៅជាតុលាការអន្តរជាតិដែលអាចអនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិដោយផ្ទាល់បានដែរ[39]។ មិនថារចនាសម្ព័ន្ធ "ដែលមានលក្ខណៈវិសាមញ្ញ" ឬ ជំនួយបច្ចេកទេសណាដែលតុលាការនេះអាចទទួលបានក៏ដោយ អ.វ.ត.ក នៅតែជាតុលាការកម្ពុជា ដែលត្រូវអនុវត្តតែច្បាប់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ[40]។

---

[37] *ដូចលេខជើងទំព័រខាងលើ* កថាខណ្ឌ ទី២១៥ ដល់ ទី២២២។

[38] នៅក្នុងការសម្រេចថា អ.វ.ត.ក គឺជាតុលាការដែលមានលក្ខណៈអន្តរជាតិ អង្គបុរេជំនុំជម្រះបានប្រើប្រាស់នូវ "ការណែនាំដែលជាយុត្តាធិការនៅតុលាការដែលមានលក្ខណៈអន្តរជាតិដទៃទៀត" *ដូចលេខជើងទំព័រខាងលើ* កថាខណ្ឌ ២១៥។ អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំក្នុងការស្វែងរកការណែនាំមកពីតុលាការដែលមានលក្ខណៈអន្តរជាតិនានា។ ការណែនាំដើម្បីកំណត់ថា អ.វ.ត.ក គឺជាតុលាការជាតិ ឬ "ដែលមានលក្ខណៈអន្តរជាតិ" ឬជាតុលាការអន្តរជាតិ អាចយកចេញពីកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ។ ទាំងរាជរដ្ឋាភិបាលកម្ពុជា ទាំងអង្គការសហប្រជាជាតិ សុទ្ធតែគ្មានចេតនាក្នុងបង្កើត អ.វ.ត.ក ឲ្យទៅជាតុលាការអន្តរជាតិ។ ដោយផ្ទុះបញ្ហាំងពីចេតនា និង លទ្ធផលនៃការចរចារ កិច្ចព្រមព្រៀងនេះមានលក្ខណៈច្បាស់លាស់ ដែលបញ្ជាក់ថា អ.វ.ត.ក គឺជាតុលាការកម្ពុជា។ ដូចគ្នានេះដែរ ច្បាប់ស្តីពីការបង្កើតតុលាការនេះ បញ្ជាក់បន្ថែមថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់..." ច្បាប់ស្តីពីការបង្កើតតុលាការ មាត្រា ២ ថ្មី។ សម្រាប់ការពិភាក្សាស៊ីជម្រៅទៅលើឋានៈរបស់ អ.វ.ត.ក ជាតុលាការជាតិ និង លទ្ធផលនានាដែលបានមកពីឋានៈបែបនេះ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី កថាខណ្ឌ ៨ ដល់ កថាខណ្ឌ ២០។ *សូមមើលផងដែរ* សារណាដែលក្រុមមេធាវីការពារក្តីនឹងដាក់ជូនចំពោះបញ្ហានេះ នៅក្នុងសារណាបន្ថែមរបស់ខ្លួនលើភាពអាចអនុវត្តបាននៃច្បាប់អន្តរជាតិ។

[39] សម្រាប់ការពិភាក្សាលើការអនុវត្តដោយផ្ទាល់នៃច្បាប់ទំនៀមទំលាប់នៅក្នុងតុលាការជាតិកម្ពុជា *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី កថាខណ្ឌ ១១១ ដល់ ១១៤ និងកថាខណ្ឌ ១២១ ដល់ ១២៥។

[40] អ.វ.ត.ក មិនត្រូវបានបង្កើតឡើងដើម្បីចោទប្រកាន់ពីបទឧក្រិដ្ឋនានា ដោយផ្អែកលើមូលដ្ឋានយុត្តាធិការជាសកលនោះទេ។ វាមានលក្ខណៈច្បាស់លាស់ស្រាប់ហើយនៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើតតុលាការនេះ ដែលថាតុលាការនេះ គឺជាតុលាការជាតិកម្ពុជា ដែលមានយុត្តាធិការរបស់ខ្លួនដូចគ្នាទៅនឹងតុលាការជាតិដទៃទៀតដែរ។ *សូមមើល* កិច្ចព្រមព្រៀង មាត្រា ២, ច្បាប់ស្តីពីការបង្កើត មាត្រា ២ ថ្មី។ *សូមមើលផងដែរ* ឯកសាររបស់ ហ៊ែនរី ឃីស៊ីនជឺ (Henry Kissinger) ស្តីពី *គុណវិបត្តិរបស់យុត្តាធិការជាសកល* ចេញផ្សាយនៅក្នុងព្រឹត្តិបត្តិ កិច្ចការបរទេស (Foreign Affairs) (ខែ កក្កដា/សីហា ឆ្នាំ

២០. បើទោះជា អ.វ.ត.ក *អាច*ដើរតួរជាតុលាការអន្តរជាតិ ហើយអនុវត្តច្បាប់ទំនៀមទំលាប់អន្តរជាតិបានដោយផ្ទាល់ក៏ដោយ ក៏មិនមានន័យថា អ.វ.ត.ក អាចសម្រេចថាព្រះរាជប្រទានលើកលែងទោស និងអនុគ្រោះទោសមិនមានសុពលភាពដែរ។ មិនមានបទដ្ឋានច្បាប់លាស់ណាមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ ដែលតុលាការអន្តរជាតិអាចអនុវត្តបាន ដើម្បីធ្វើមោឃភាពលើការអនុគ្រោះទោស ឬការលើកលែងទោសដែលត្រូវបានផ្តល់ឲ្យដោយមានសុពលភាពនោះទេ[41]។

---

២០០៦) "ប្រព័ន្ធបែបនេះ [យុត្តាធិការជាសកល] ចេញហួសឆ្ងាយពីអាណត្តិជាក់លាក់ និង មានកំហិតរបស់ក្រុមសន្តិសុខអង្គការសហប្រជាជាតិ ចំពោះតុលាការនានាដែលដោះស្រាយលើឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងអតីតប្រទេសយូហ្គូស្លាវី និង រ៉ាវ៉ាន់ដា ក៏ដូចជាតុលាការដែលកំពុងត្រូវបានចរចារបង្កើតសម្រាប់ប្រទេសកម្ពុជា" (គូសបញ្ជាក់បន្ថែម)។ ចំណុចនេះ វាខុសពីតុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន ដែលត្រូវបានបង្កើតឡើងយ៉ាងជាក់ច្បាស់ ដើម្បីអនុវត្តនូវយុត្តាធិការជាសកល។ *សូមមើល* សាលដីការបស់តុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន លើរឿងក្តីរបស់ Lome Accord កថាខណ្ឌ ៨៨។ តុលាការពិសេសនេះ ត្រូវបានបង្កើតឡើងក្នុងលក្ខណៈបែបនេះ ពីព្រោះ ដោយយោងទៅលើកិច្ចព្រមព្រៀង Lome គេឃើញមានការរំលោភបំពានទៅលើកិច្ចព្រមព្រៀងនេះដោយអ្នកដែលបានទទួលផលប្រយោជន៍ពីការអនុគ្រោះទោសដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនោះ មានន័យថា ការប្រយុទ្ធនៅតែបន្ត។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង សេសាសេ និងអ្នកដទៃទៀត* ឯកសារលេខ SCSL-04-15-T សាលក្រម ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៩០៨ ដល់ ៩១៤។ ដោយសារតែការបន្តប្រយុទ្ធនោះ រដ្ឋាភិបាលប្រទេសសេរ៉ា ឡេអូន បានសម្រេចព្យាយាមបញ្ចុះបញ្ចូលឲ្យបង្កើតតុលាការអន្តរជាតិមួយ។ *សូមមើល* សេចក្តីសម្រេចក្រុមព្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣១៥ ឯកសារអង្គការសហប្រជាជាតិលេខ S/RES/1315 (ឆ្នាំ ២០០០) ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០០ បុព្វកថា។ តុលាការអន្តរជាតិណាមួយ នឹងបង្កើតឲ្យមានមធ្យោបាយជុំវិញការអនុគ្រោះទោស ដូចដែលបានផ្តល់ឲ្យនៅក្នុងកិច្ចព្រមព្រៀង Lome ដោយសារតែភាពមានកម្រិតរបស់អង្គការសហប្រជាជាតិ ដែលមិនទទួលយកថាការអនុគ្រោះទោសនឹងអនុវត្តចំពោះបទប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ *សូមមើល* សាលដីកាតុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន លើរឿងក្តី Lome Accord កថាខណ្ឌ ៨៩។

[41] *សូមមើល ជាឧទាហរណ៍* ឯកសាររបស់ ចន ឌូហ្គាដ (John Dugard) ស្តីពី *ការដោះស្រាយចំពោះឧក្រិដ្ឋកម្មរបស់របបចាស់៖ តើការអនុគ្រោះទោសនៅតែជាជម្រើសមួយដែរឬទេ?* បោះពុម្ពដោយ 12 Leiden J. Int'L L. 1001 (ឆ្នាំ ១៩៩៩) ("ឌូហ្គាដ៖ *ការដោះស្រាយចំពោះឧក្រិដ្ឋកម្មរបស់របបចាស់*")។ ឯកសាររបស់ ឡីឡា ណាដ្យា សាដាត (Leila Nadya Sadat) ស្តីពី *ការនិរទោស, ការអនុគ្រោះទោស, និងច្បាប់អន្តរជាតិ* បោះពុម្ពដោយ 81 Notre Dame L. Rev. ទំព័រ ៩៥៥ និង ១០២២ (ឆ្នាំ ២០០៦) ("សាដាត៖ *ការអនុគ្រោះទោស, និងច្បាប់អន្តរជាតិ*")។ សាស្ត្រាចារ្យ ឌូហ្គាដ លើកឡើងថា "របបដែលជាសន្តតិជននៃរបបមុន នាពេលបច្ចុប្បន្ននេះ ត្រូវបានប្រាប់ដោយស្ថាប័នកំពូលនៃមតិសាធារណៈ ដែលមានដូចជា អង្គការក្រោមរដ្ឋាភិបាល NGOs និង អ្នកប្រាជ្ញ ថាមិនត្រឹមតែរបបនេះ *គួរតែ* ចោទប្រកាន់នោះទេ ថែមទាំង *មានកាតព្វកិច្ច* ក្រោមច្បាប់អន្តរជាតិក្នុងការចោទប្រកាន់ផងដែរ... អ្វីដែលគេអាចយល់បានពីទឡ្ហីករណ៍មួយនេះគឺថា ច្បាប់អន្តរជាតិរារាំងការអនុគ្រោះទោស។ ចំណុចនេះត្រូវបញ្ជាក់យ៉ាងច្បាស់ដោយតុលាការជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង ហ្វ៊ូរុនហ្ស៊ីចា (Furundzija)* ដែលបានសម្រេចថា ការអនុគ្រោះទោសសម្រាប់អំពើទារុណកម្ម

នៅក្នុងឆ្នាំ ២០០៤ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានយល់ឃើញថា បទដ្ឋានដែលរដ្ឋាភិបាលមិនអាចផ្តល់ការអនុគ្រោះទោស ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិបាននោះ គឺ "កំពុងអភិវឌ្ឍន៍នៅក្រោមច្បាប់អន្តរជាតិ"[42]។ បទដ្ឋានបែបនេះមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ[43]។

---

ត្រូវចាត់ទុកជាមោឃៈ និង មិនត្រូវទទួលបាននូវការទទួលស្គាល់ពីបរទេសឡើយ។ ប៉ុន្តែ វាមានវិមតិសង្ស័យ ថាតើច្បាប់អន្តរ-ជាតិបានវិវឌ្ឍន៍មកដល់ដំណាក់កាលនេះហើយឬនៅ។ ការអនុវត្តរបស់រដ្ឋ មិនទំនងជាគាំទ្រដល់ច្បាប់បែបនេះឡើយ ពីព្រោះថា ប្រវត្តិសាស្ត្រសម័យទំនើប ពោពេញទៅដោយករណីជាច្រើន ដែលបង្ហាញថា របបដែលជាសន្តតិជនបានផ្តល់ការអនុគ្រោះទោសដល់មន្ត្រីនៃរបបចាស់ ដែលមានពិរុទ្ធភាពចំពោះអំពើទារុណកម្ម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងធ្វើការចោទប្រកាន់ពួកគាត់ទាំងនោះ។ នៅក្នុងករណីជាច្រើនក្នុងចំណោមករណីទាំងអស់នេះ ជាពិសេសករណីអាហ្វ្រិកខាងត្បូង អង្គការសហប្រជាជាតិស្វាគមន៍ចំពោះដំណោះស្រាយបែបនេះ។ សេចក្តីសម្រេចរបស់តុលាការជាតិក៏អាចផ្តល់ឲ្យនូវភស្តុតាងស្តីពីការអនុវត្តរបស់រដ្ឋ ហើយត្រង់ចំណុចនេះ គេត្រូវសង្កត់ធ្ងន់ថា តុលាការជាតិដែលមានធម្មនុញ្ញភាព តម្កល់ជាទូទៅ នូវសុពលភាពនៃការច្បាប់ស្តីពីការអនុគ្រោះទោស។ មានពេលខ្លះ ដូចនៅក្នុងរណីតុលាការនៅអាហ្វ្រិកខាងត្បូង និង អ៊ែល សាលវាឌ័រ (El Salvador) ដែលបង្ហាញពីការយល់ឃើញថា ច្បាប់អន្តរជាតិមិនត្រឹមតែខកខានក្នុងការរារាំងការអនុគ្រោះទោសប៉ុណ្ណោះនោះទេ វាផ្ទុយទៅវិញបែរជាជំរុញឲ្យមានការអនុគ្រោះទោស"។ ឯកសាររបស់ ឌូហ្គាដ៖ *ការដោះស្រាយចំពោះឧក្រិដ្ឋកម្មរបស់របបចាស់* ត្រង់ទំព័រ ១០០២ ដល់ទំព័រ ១០០៤ (គូសបញ្ជាក់បន្ថែម)។ សាស្ត្រាចារ្យ សាដាត លើកឡើងថា "លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិមានលក្ខណៈច្បាស់លាស់ចំពោះការជំទាស់តវ៉ាជាក់លាក់មួយចំនួនលើការទទួលខុសត្រូវ ដូចជាបញ្ហាការរបស់ថ្នាក់លើ អភ័យឯកសិទ្ធិរបស់ប្រមុខរដ្ឋ និង អាជ្ញាយុកាល ប៉ុន្តែលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនបានចែងពីតួនាទីក្នុងការចោទប្រកាន់ និងបញ្ហាពាក់ព័ន្ធនឹងការអនុគ្រោះទោស។ បើទោះជាបញ្ហានេះត្រូវបានលើកឡើងនៅក្នុងសន្និសិតទីក្រុងរ៉ូមដែលលក្ខន្តិកៈនេះត្រូវបានអនុម័តក៏ដោយ ក៏មិនមានការយល់ស្របគ្នាច្បាស់លាស់ណាមួយ ត្រូវបានធ្វើឡើងក្នុងចំណោមប្រតិភូជំវិញបញ្ហាថាតើចំណុចនេះត្រូវដោះស្រាយបែបណានោះដែរ។ ចំណុចនេះក៏ស្នើឡើងផងដែរថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេលើបញ្ហានេះ យ៉ាងហោចណាស់គិតមកត្រឹមឆ្នាំ ១៩៩៨" ឯកសាររបស់ សាដាត៖ *ការអនុគ្រោះទោស និង ច្បាប់អន្តរជាតិ* ត្រង់ទំព័រ ១០២២ (គូសបញ្ជាក់បន្ថែម)។

[42] សាលដីកាតុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន លើរឿងក្តី Lome Accord កថាខណ្ឌ ៨២ (គូសបញ្ជាក់បន្ថែម)។

[43] *ដូចលេខជើងទំព័រខាងលើ*។ សម្រាប់ការពិភាក្សាលើបញ្ហាថាតើហេតុអ្វីតុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន ត្រូវបែងចែកថាខុសពី អ.វ.ត.ក និងថាតើហេតុអ្វីសេចក្តីសម្រេចរបស់តុលាការពិសេសសម្រាប់ប្រទេស សេរ៉ា ឡេអូន ដែលមិនទទួលស្គាល់នូវការអនុគ្រោះទោសសម្រាប់ឧក្រិដ្ឋកម្មដែលមានលក្ខណៈអាជ្ញាបញ្ញា មិនបង្ហាញថាការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មបែបនេះមិនចាត់ទុកជាមោឃៈទេនោះ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី កថាខណ្ឌ ៧៥ ដល់ ៨២។ បើទោះជារដ្ឋមួយចំនួន បានធ្វើមោឃភាពលើការអនុគ្រោះទោសដែលត្រូវបានផ្តល់ឲ្យក៏ដោយ ក៏មិនមានការអនុវត្តរបស់រដ្ឋជាទូទៅ និង ស្របគ្នាចំពោះបញ្ហានេះដែរ រួមទាំង គោលការណ៍ *opinio juris* ដែលចាំបាច់ក្នុងការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

២១. ប្រសិនបើបទឧក្រិដ្ឋត្រូវបានកំណត់ថាជាអាជ្ញាបញ្ញា (*jus cogens*) នោះឋានៈនេះតម្រូវឲ្យរដ្ឋមិនពាក់ព័ន្ធវាទេ ប៉ុន្តែមិនចាំបាច់ថាតម្រូវឲ្យរដ្ឋកាត់ទោសការប្រព្រឹត្តបទឧក្រិដ្ឋនេះទេ។ បច្ចុប្បន្ន ពុំមាននិយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលតម្រូវឲ្យរដ្ឋកាត់ទោសការប្រព្រឹត្តឧក្រិដ្ឋកម្ម *អាជ្ញាបញ្ញា* (*jus cogens*)ឡើយ[44]។ ប្រសិនបើ ការកាត់ទោសចំពោះបទឧក្រិដ្ឋបែបនេះពុំបានទទួលនូវឋានៈច្បាប់ទំនៀមទម្លាប់អន្តរជាតិទេនោះ អសុពលភាពនៃការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋបែបនេះមិនអាចទទួលបាននូវឋានៈបែបនេះឡើយ។ សូម្បីតែព្រះរាជអាជ្ញាជនជាតិហូឡង់ឈ្មោះ Ward Ferdinandusse ដែលជឿជាក់ថា "ច្បាប់ទំនៀមទម្លាប់អន្តរជាតិបច្ចុប្បន្ន ពិតជាបានដាក់ករណីយកិច្ចទៅលើរដ្ឋ ក្នុងការផ្តន្ទាទោសរាល់បទឧក្រិដ្ឋស្នូលដែលបានប្រព្រឹត្តក្នុងដែនយុត្តាធិការរបស់ពួកគេ"[45] បានសន្និដ្ឋានថា ច្បាប់ស្តីពីការអនុគ្រោះទោសអាចត្រូវបានចាត់ទុកថាជាករណីលើកលែងមួយចំពោះករណីយកិច្ចនេះ ជាជាងជាការបំពារបំពានទៅលើករណីយកិច្ចនេះ[46]។

២២. ការដែលអង្គការសហប្រជាជាតិមិនដែលថ្លែងថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស ពុំមានសុពលភាព និងមិនសាកសួរអំពីសុពលភាពនៃព្រះរាជក្រឹត្យនេះនៅពេលព្រះរាជក្រឹត្យត្រូវបានផ្តល់ឲ្យ ឬនៅពេលដែលកិច្ចព្រមព្រៀងនេះត្រូវបានចរចា ជាភស្តុតាងបង្ហាញថាពុំមាននិយាមដែលមានលក្ខណៈច្បាស់លាស់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលហាមប្រាម

---

[44] "ក្រៅពីគ្មានវិធានទំនៀមទម្លាប់ដែលមានខ្លឹមសារទូទៅ គ្មានគោលការណ៍អន្តរជាតិទូទៅអាចរកបាន ដែលអាចពឹងអាស្រ័យបាន ដើម្បីគូសបញ្ជាក់ថា កាតព្វកិច្ចក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មអន្តរជាតិមានលក្ខណៈច្បាស់លាស់ក្នុងសហគមន៍អន្តរជាតិ" ANTONIO CASSESE, INTERNATIONAL CRIMINAL LAW 302 (Oxford University Press 2003)។ សម្រាប់ការវិភាគបន្ថែមលើចំណុចនេះ។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ១២៦-២៩។

[45] ឯកសាររបស់ WARD N. FERDINANDUSSE ស្តីពី *ការអនុវត្តដោយផ្ទាល់នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងតុលាការជាតិ ២០២* (T.M.C. Asser Press ឆ្នាំ២០០៦) (គូសបញ្ជាក់បន្ថែម)។ ទោះជាយ៉ាងនេះក្តី គាត់មិនជឿថា នេះត្រូវបានបង្កើតឡើងក្នុងនាមជាករណីយកិច្ចទូទៅមួយ ក្នុងការផ្តន្ទាទោស ឬធ្វើបត្យាប័នឧក្រិដ្ឋករស្នូលទាំងអស់។ *ដូចជើងទំព័រខាងលើ*។

[46] ដូចជើងទំព័រខាងលើ កថាខណ្ឌ២០០។ FERDINANDUSSE កត់សម្គាល់ថា ការអនុគ្រោះទោសអាចត្រូវបានផ្សះផ្សាជាមួយនឹងករណីយកិច្ចមួយ ក្នុងការផ្តន្ទាទោស បន្ថែមលើលក្ខខណ្ឌនៃការអនុគ្រោះទោសផ្ទុះបញ្ចាំងពីតុល្យភាពសមស្របនៃផលប្រយោជន៍ខុសៗគ្នាដែលពាក់ព័ន្ធ។ លោកថ្លែងថា "ការពិតនេះត្រូវបានបង្ហាញយ៉ាងសមស្របដោយលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលក្នុងន័យទូទៅ ទទួលស្គាល់អំពីភាពចាំបាច់ ក្នុងការផ្តន្ទាទោស ប៉ុន្តែនៅពេលដូចគ្នាដែរអនុញ្ញាតឲ្យមានឆន្ទានុសិទ្ធិរដ្ឋអាជ្ញា ហើយធ្វើស្ងាត់ស្ងៀមចំពោះអត្រានុគោលភាព និងអានុភាពនៃការអនុគ្រោះទោស ពីព្រោះរដ្ឋដែលជាភាគីចរចាអាចឈានដល់កិច្ចព្រមព្រៀងត្រង់ចំណុចនោះ"។ *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២០១។

ការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ។ ប្រសិនបើអង្គការសហប្រជាជាតិប្រកាន់យកគោលជំហរដែលថា ព្រះរាជក្រឹត្យពុំមានសុពលភាព កិច្ចព្រមព្រៀងគួរបានឆ្លុះបញ្ចាំងពីចំណុចនេះ។ អង្គការសហប្រជាជាតិគួរតែបានបន្ថែមការបញ្ជាក់មួយទៅនឹងកិច្ចព្រមព្រៀង ដូចដែលខ្លួនបានធ្វើក្នុងកិច្ចព្រមព្រៀង Lomé[47] ប៉ុន្តែអង្គការសហប្រជាជាតិពុំមានធ្វើដូច្នេះឡើយ។

២៣. ការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានគាំទ្រដោយអង្គការសហប្រជាជាតិ ដែលគួរបញ្ជាក់បន្ថែមទៀតថា ពុំមាននិយាមដែលមានលក្ខណៈច្បាស់លាស់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ប្រឆាំងនឹងការអនុគ្រោះទោសបែបនេះ។ ក្នុងឆ្នាំ ១៩៩៦ ជាឆ្នាំដែលព្រះរាជក្រឹត្យនេះត្រូវបានចេញនៅកម្ពុជា រដ្ឋាភិបាលសៀរ៉ាឡេអូនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយរណសិរ្សបង្រួបបង្រួមបដិវត្តន៍សៀរ៉ាឡេអូន ("RUF") នៅទីក្រុង Abidjan ដែលផ្តល់ការអនុគ្រោះទោសទូទៅចំពោះបទឧក្រិដ្ឋទាំងអស់ដែលបានប្រព្រឹត្តដោយ RUF ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់អន្តរជាតិ[48]។ អង្គការសហប្រជាជាតិក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះផងដែរ ក្នុងនាមជាអ្នកធានាខាងផ្នែកស្មារតី[49]។

## គ. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំនៅក្នុងការកំណត់ថា វិសាលភាពនៃព្រះរាជក្រឹត្យពុំបានការពារលោក អៀង សារី ពីការកាត់សេចក្តីនៅអង្គជំនុំជម្រះវិសាមញ្ញ

---

[47] ក្រោយពេលកិច្ចព្រមព្រៀង Lomé អង្គការសហប្រជាជាតិបានទទួលស្គាល់ចំណារដោយដៃមួយ ដោយថ្លែងការណ៍ថា អង្គការសហប្រជាជាតិ "ទទួលស្គាល់ថា បទប្បញ្ញត្តិនៃការលើកលែងទោសនៅក្នុងកិច្ចព្រមពៀងនោះមិនត្រូវអនុវត្តចំពោះបទឧក្រិដ្ឋអន្តរជាតិនានា ដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានធ្ងន់ធ្ងរដទៃទៀតទៅលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ"។ *សូមមើល* សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ 1315 ឯកសារ S/RES/1315 (2000) ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០០ បុព្វកថា។ បន្ទាប់ពីទទួលបានលិខិតព្រមាននេះ អង្គការសហប្រជាជាតិបានអនុម័តសេចក្តីសម្រេចមួយស្វាគមន៍ដល់កិច្ចព្រមព្រៀង Lomé ហើយកម្រនឹងមានការលើកឡើងអ្វីអំពីលិខិតនេះ។ សម្រាប់ការពិភាក្សាបន្ថែមលើឥរិយាបទរបស់អង្គការសហប្រជាជាតិចំពោះកិច្ចព្រមព្រៀង Lomé។ សូមមើល បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ ៧៧-៧៩។

[48] កិច្ចព្រមព្រៀង Abidjan ធានាថា "មិនមានអាជ្ញាផ្លូវការណាមួយ ឬអាជ្ញាផ្នែកតុលាការ ណាមួយត្រូវបានធ្វើឡើងប្រឆាំងនឹងសមាជិកណាមួយនៃក្រុម RUF ទាក់ទិននឹងសកម្មភាពរបស់ពួកគេ ដែលអនុវត្ត តាមគោលដៅរបស់ខ្លួន ក្នុងនាមជាសមាជិករបស់អង្គការទាំងនោះ រហូតដល់ពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ"។ កិច្ចព្រមព្រៀងសន្តិភាព Abidjan រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសៀរ៉ាឡេអូន និងរណសិរ្សបង្រួបបង្រួមបដិវត្តន៍សៀរ៉ាឡេអូន ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ មាត្រា១៤ ដែលអាចរកបានតាមអាសយដ្ឋាន http://www.sierra-leone.org/abidjanaccord.html.

[49] *ដូចជើងទំព័រខាងលើ* មាត្រា១៤។

**១. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំនៅក្នុងការយល់ថា អនុភាពតែមួយគត់នៃការលើកលែងទោសនេះ គឺការលុបចោលការដាក់ទោសដែលលោក អៀង សារី បានទទួលក្នុងឆ្នាំ១៩៧៩**

២៤. អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានសញ្ញាណាមួយដែលថា ការលើកលែងទោសគ្របដណ្តប់ការផ្តន្ទាទោសណាមួយចំពោះអំពើ ដែលបានជំនុំជម្រះនៅក្នុងសវនាការកាលពីឆ្នាំ១៩៧៩នោះឡើយ[50]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការយល់ថាពាក្យការលើកលែងទោស ថាជាការអនុគ្រោះទោសពីការចោទប្រកាន់ចំពោះអំពើនានា ដែលត្រូវបានជំនុំជម្រះនៅក្នុងឆ្នាំ១៩៧៩ ពុំមែនជាបំណងរបស់ព្រះរាជក្រឹត្យនោះឡើយ ព្រោះព្រះរាជក្រឹត្យនេះមានលក្ខណៈច្បាស់លាស់ គឺសំដៅទៅលើច្បាប់ឆ្នាំ១៩៩៤ នៅពេលលើកឡើងអំពីការអនុគ្រោះទោសពីការចោទប្រកាន់[51]។

២៥. ដូចបានពន្យល់នៅខាងលើ[52] ការបកស្រាយរបស់អង្គបុរេជំនុំជម្រះទៅលើការលើកលែងទោស ថាគ្របដណ្តប់តែចំពោះការកាត់ទោសនោះ មានលក្ខណៈចង្អៀតជ្រុលពេក និងមិនស្របគ្នានឹងអត្ថបទជាភាសាខ្មែរ។ ការលើកលែងទោសនេះចាំបាច់ត្រូវបកស្រាយថាការមិនយកពិរុទ្ធលើរូបលោក អៀង សារី ចំពោះបទឧក្រិដ្ឋនានាដែលត្រូវបានជំនុំជម្រះក្នុងឆ្នាំ១៩៧៩។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងកំណត់ថា ការបកស្រាយទៅលើការលើកលែងទោសនេះមិនច្បាស់លាស់ ដូច្នេះត្រូវពិចារណាទៅលើចេតនានៃអ្នកដែលបានចរចា និងរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះ។ ក្នុងសេចក្តីថ្លែងការណ៍របស់គាត់ លោក អៀង សារី បានថ្លែងថា "គេបានសង្កត់ធ្ងន់ថា ខ្ញុំដាច់ខាតត្រូវតែមានការលើកលែងទោស (Pardon) ពីការផ្តន្ទាទោសនាឆ្នាំ១៩៧៩...ទៅលើអំពើដែលខ្លួនខ្ញុំបានប្រព្រឹត្ត រួមទាំងអំពើនានាដែលត្រូវបានយកមកកាត់សេចក្តីនៅក្នុងសវនាការឆ្នាំ១៩៧៩"[53]។ សេចក្តីថ្លែងការណ៍របស់លោក អៀង សារី ផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូងនូវការចង្អុលបង្ហាញយ៉ាងច្បាស់លាស់អំពីចេតនារបស់អ្នកចរចា និងអ្នករៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ដែលថា ការលើកលែងទោសគឺគ្របដណ្តប់លើរាល់ការកាត់ទោសដែលពាក់ព័ន្ធនឹងការផ្តន្ទាទោសដោយផ្អែកទៅលើអំពើនានាដែលត្រូវបានជំនុំជម្រះក្នុងឆ្នាំ១៩៧៩។

---

[50] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៩១។

[51] *ដូចជើងទំព័រខាងលើ*។

[52] *សូមមើល ជើងទំព័រខាងលើ* កថាខណ្ឌ៣-៨។

[53] សេចក្តីថ្លែងការណ៍របស់ អៀង សារី (គូសបញ្ជាក់បន្ថែម)។

បន្ថែមលើនេះទៀត អតីតសហនាយករដ្ឋមន្ត្រី សម្តេច ហ៊ុន សែន និងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ពិតជាដឹងថា លោក អៀង សារី នឹងមិនព្រមធ្វើសមាហរណកម្មឡើយ ប្រសិនបើពុំមានការការពារសមស្របចំពោះរូបគាត់នោះ[54]។

**២. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំនៅក្នុងការយល់ថា ការអនុគ្រោះទោសមិនរារាំងដល់ការផ្តន្ទាទោសចំពោះលោក អៀង សារី នៅអង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជា**

**ក. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំនៅក្នុងការយល់ថា ច្បាប់ឆ្នាំ១៩៩៤មិនគ្របដណ្តប់លើរាល់បទឧក្រិដ្ឋនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

២៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ច្បាប់ឆ្នាំ១៩៩៤ បានកំណត់ថាជាបទឧក្រិដ្ឋចំពោះបទល្មើសមួយចំនួន ដូចជា បទល្មើសប្រឆាំងនឹងសន្តិសុខផ្ទៃក្នុងប្រទេស ហើយក៏អាចកំណត់ថាជាបទឧក្រិដ្ឋចំពោះសមាជិកភាពក្នុងក្រុម "កម្ពុជាប្រជាធិបតេយ្យ"[55]ផងដែរ។ អង្គជំនុំជម្រះបានយល់ឃើញថា "មិនមានការបង្ហាញណាមួយដែលថា ការចោទប្រកាន់ទៅលើបទឧក្រិដ្ឋដទៃទៀត នឹងត្រូវបញ្ឈប់មិនឲ្យមានការចោទប្រកាន់ តាមក្រមព្រហ្មទណ្ឌដែលចូលជាធរមានរួចមកហើយ ដូចមានការគូសបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងមាត្រា៣នោះដែរ"[56]។ អង្គជំនុំជម្រះបានសន្និដ្ឋានថា

---

[54] គេបានរាយការណ៍ថា "ក្នុងសន្និសីទកាសែតមួយ លោក អៀង សារី បានថ្លែងថា គោលបំណងចម្បងរបស់គាត់គឺដើម្បីទទួលបានការអនុគ្រោះទោស។ ល្គឹកណាដែលគាត់ទទួលបានការអនុគ្រោះ ទើបលោកនឹងបន្តការចរចា"។ ការអនុគ្រោះទោសចំពោះ អៀង សារី UNOSGR0690 ថ្ងៃទី៩-១៥ ខែកញ្ញា ឆ្នាំ១៩៩៦ កថាខណ្ឌ២។

[55] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៩៦-៩៧ និង ២០០។

[56] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៩៧។ គេក៏បានរកឃើញដែរថា សាលក្រមក្នុងសំណុំរឿង ឈូក រិន មិនបានគាំទ្រដល់ការបកស្រាយផ្សេងឡើយ។ *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៩៨។ ក្រុមមេធាវីការពារនឹងមិនលើកចំណុចនេះឡើង ត្បិតខ្លួនឯកភាពថា សាលាក្រមក្នុងសំណុំរឿង ឈូក រិន មានសារៈប្រយោជន៍បំផុត ក្នុងការកំណត់<u>វិសាលភាពពេលវេលា</u> នៃច្បាប់ឆ្នាំ១៩៩៤។ វិសាលភាពពេលវេលានៃច្បាប់ឆ្នាំ១៩៩៤មិនត្រូវបានលើកឡើងក្នុងនេះឡើយ ព្រោះអង្គបុរេជំនុំជម្រះមិនបានលើកឡើងអំពីបញ្ហានេះ ហើយហាក់ដូចជាបានទទួលស្គាល់ថា វិសាលភាពពេលវេលានៃច្បាប់ឆ្នាំ១៩៩៤ រួមបញ្ចូលទាំងឆ្នាំ១៩៧៥-១៩៧៩។ ក្រុមមេធាវីការពារក្តីបានត្រៀមខ្លួនរៀបចំលើកឡើងបញ្ហានេះនៅសវនាការបឋម ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា នេះនឹងក្លាយជាជំនួយ។ មានភស្តុតាងបន្ថែមថា ច្បាប់ឆ្នាំ១៩៩៤មានចេតនាគ្របដណ្តប់លើអំឡុងពេល១៩៧៥-១៩៧៩ តែទោះជាយ៉ាងណាក្តី មានរបាយការណ៍ថា ក្នុងឆ្នាំ ២០០០ លោក សម រង្ស៊ី ដែលធ្លាប់ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុក្នុងឆ្នាំ១៩៩៤ និងបានចូលរួមក្នុងការពិភាក្សាដេញដោលនៅរដ្ឋសភាស្តីពីច្បាប់ឆ្នាំ១៩៩៤ បានផ្តល់ការវាយតម្លៃផ្ទាល់ខ្លួនរបស់លោកអំពីចេតនានៃច្បាប់នេះ នៅពេលដែលរដ្ឋសភាអនុម័តការផ្តល់ការអនុគ្រោះទោស។ លោកបានអះអាងថាច្បាប់នេះមានចេតនាផ្តល់

បទល្មើសដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ មិនអាចកំណត់ជាបទល្មើសតាមច្បាប់ឆ្នាំ១៩៩៤ បានឡើយ ហើយនឹងត្រូវបន្តផ្ដន្ទាទោសតាមច្បាប់ដែលនៅជាធរមាន[57]។

**ច្បាប់ឆ្នាំ១៩៩៤ - បុព្វកថា**

២៧. ច្បាប់ឆ្នាំ១៩៩៤ចាំបាច់ត្រូវយកមកពិចារណាទាំងស្រុង[58]។ អង្គបុរេជំនុំជម្រះពុំផ្ដល់ការគាំទ្រអ្វីចំពោះការយល់ឃើញរបស់ខ្លួនដែលថា "បទល្មើសដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្លូវសាសនាដែលជាបទល្មើសជាតិ មិនអាចកំណត់ជាបទល្មើសតាមច្បាប់ឆ្នាំ១៩៩៤បានឡើយ [59]។ ផ្ទុយទៅវិញ បុព្វកថានៃច្បាប់ឆ្នាំ១៩៩៤ចែងយ៉ាងច្បាស់ថា ច្បាប់នេះត្រូវបានអនុម័ត "ដោយយល់ឃើញថា មេដឹកនាំនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ" មិនអាច... <u>សម្រាប់លាក់បំបាំង យករួចខ្លួនពីការទទួលខុសត្រូវរបស់ពួកខ្លួន ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យ ពូជសាសន៍</u> ចាប់តាំងពីពេលរបប ប៉ុល ពត ដណ្ដើមអំណាចនៅឆ្នាំ១៩៧៥-១៩៧៨។ បទឧក្រិដ្ឋ<u>ប្រល័យពូជសាសន៍</u>គ្មានអាជ្ញាយុកាលឡើយ"[60]។

---

ការអនុគ្រោះទោសតែចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមុនពេលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ប៉ុណ្ណោះ ហើយថា <u>រដ្ឋសភាបានចាំយ៉ាងច្បាស់នូវបទឧក្រិដ្ឋដែលបានកើតឡើងក្នុងអំឡុងរបបគ្រប់គ្រងខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩។</u> អត្ថបទរបស់ Gina Chon & Van Roeun, *Chhouk Rin Verdict Sets Uncertain Precedent for Other KR*, CAMBODIA DAILY ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០។

[57] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ១៩៩-២០០។

[58] ច្បាប់ឆ្នាំ១៩៩៤ចាំបាច់ត្រូវបានយកពិចារណាទាំងស្រុង ប្រសិនបើច្បាប់នេះត្រូវបានគេយល់ថាមិនមានភាពច្បាស់លាស់នោះ។ វិធានទូទៅគឺថា "នៅពេលអត្ថបទច្បាប់មួយមានភាពមិនច្បាស់លាស់ ឬស្រពិចស្រពិល តុលាការនឹងពិចារណាទៅលើឆន្ទៈរបស់ស្ថាប័ននីតិប្បញ្ញត្តិ។ ចំពោះករណីនោះ ដំបូង ចៅក្រមនឹងពិនិត្យមើលទៅលើអត្ថបទច្បាប់ដោយយកចិត្តទុកដាក់ បន្ទាប់មកនឹងពិចារណាទៅលើសេចក្ដីអធិប្បាយនានាដែលបានសរសេរទាក់ទិននឹងអត្ថបទច្បាប់នោះ។ <u>ចំណុចនេះមិនកំហិតត្រឹមតែបញ្ញត្តិមួយដែលស្រពិចស្រពិលប៉ុណ្ណោះទេ តែក៏ត្រូវអនុវត្តចំពោះជំពូកទាំងមូល ឬច្បាប់ទាំងមូលដែរ</u>។ ជារឿយៗ បញ្ញត្តិមួយស្រពិចស្រពិល លុះត្រាតែវាដាច់ចេញពីបរិបទរបស់វា" Germain, *Statutory Interpretation* ទំព័រ២០១-០២។ សម្រាប់ការពន្យល់បន្ថែម អំពីភាពចាំបាច់ក្នុងការពិចារណាទៅលើបុព្វកថារបស់ច្បាប់ឆ្នាំ១៩៩៤ សូមមើលបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ ៨៧។

[59] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ១៩៩។

[60] ច្បាប់ឆ្នាំ១៩៩៤ បុព្វកថា (គូសបញ្ជាក់បន្ថែម)។

២៨. បុព្វកថានៃច្បាប់ឆ្នាំ១៩៩៤ក៏បានពន្យល់ដែរថា ក្រុមកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តជាបន្តបន្ទាប់នូវ "ឧក្រិដ្ឋកម្ម ភេរវកម្ម និងអំពើប្រល័យពូជសាសន៍ ដែលជាចរិតពិតរបស់ក្រុមខ្លួន តាំងពីក្រុមខ្លួនដណ្តើមយកអំណាចកាន់កាប់នៅខែមេសា ឆ្នាំ១៩៧៥ ជម្លៀសប្រជារាស្ត្រ ចាប់ខ្លួនសម្លាប់រង្គាល ហើយក្រោយមក លួចប្លន់ ដាក់មីន ពាសវាលពាសព្រៃគ្រប់ទិសទី បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន ដឹកនាំកាប់សម្លាប់ប្រជារាស្ត្រ វាយទន្ទ្រានយកទឹកដីជាតិ កាន់កាប់ដោយខុសច្បាប់ និងលក់សម្បត្តិទ្រព្យធម្មជាតិដោយរំលោភទៅលើអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា"[61]។ បទឧក្រិដ្ឋដូចមានយោងក្នុងច្បាប់ឆ្នាំ១១៩៤ មានលក្ខណៈទូលំទូលាយ និងរួមបញ្ចូលនូវអំពើជាមូលដ្ឋាននានា ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរ[62]។

## ច្បាប់ឆ្នាំ១៩៩៤ - មាត្រា៣

២៩. មាត្រា៣នៃច្បាប់ឆ្នាំ១៩៩៤ចែងថា៖

សមាជិកអង្គការនយោបាយ និងកម្លាំងយោធារបស់ក្រុម "កម្ពុជាប្រជាធិបតេយ្យ" ឬជនណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ធ្វើមនុស្សឃាត ដោយចេតនា ចាប់បង្ខំនារីសេពសន្ថវៈ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងឯកជន។ល។ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[63]។

---

[61] ដូចជើងទំព័រខាងលើ។

[62] ការបកស្រាយនេះក៏ត្រូវបានធ្វើឡើងដោយលោកសាស្ត្រាចារ្យ Stan Starygin ដែលពិភាក្សាពីការលើកលែងទោសដែលបានផ្តល់ឲ្យដោយច្បាប់ឆ្នាំ១៩៩៤ ថា "ច្បាប់ឆ្នាំ១៩៩៤ផ្តល់នូវក្តីករុណាដ៏ទូលាយក្នុងរឿងក្តី ដោយចែងថា ការលើកលែងនឹងត្រូវលាតសន្ធឹងដល់ទៅ "បទឧក្រិដ្ឋដែល [សមាជិកក្រុមកម្ពុជាប្រជាធិបតេយ្យ] បានប្រព្រឹត្ត" ដោយពុំមានកំហិតឧប្រការនេះជាបណ្តោះអាសន្ន ឬកំហិតត្រឹមលក្ខណ្ឌសំខាន់ៗ . . . ឡើយ។ ទោះបី មិនមានសំណួរថាតើ "អំពើប្រល័យពូជសាសន៍" និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀតដែលមានរៀបរាប់ក្នុងបុព្វកថានៃច្បាប់ឆ្នាំ១៩៩៤ត្រូវបានចាត់ថ្នាក់ជា *ទ្រឹស្តីច្បាប់* ហើយអាចផ្តន្ទាទោសបានក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏បទល្មើសទាំងនោះមិនអាចផ្តន្ទាទោសនៅក្នុងយុត្តាធិការនេះបានឡើយ [បើយោងទៅលើការលើកលែងទោសដែលមានចែងក្នុងមាត្រា៥] អត្ថបទរបស់ Stan Starygin, *Should the Rudolph Höss of Cambodia be Entitled to the Minimum Procedural Guarantees?*, CAMBODIAN L. REV. 1, 5-6 (2007)។ សម្រាប់ការពិភាក្សាបន្ថែមអំពីវិសាលភាពនៃបទឧក្រិដ្ឋដែលគ្របដណ្តប់ សូមមើល សារណារបស់លោក អៀង សារី អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់ របស់សហមេធាវីសុំការពន្យារពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៨ ឯកសារ C22/I/26 កថាខណ្ឌ២៦-៣០ និងបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី កថាខណ្ឌ ៤០-៤៤។

[63] គូសបញ្ជាក់បន្ថែម។

៣០. មាត្រានេះពុំកម្រិតបទឧក្រិដ្ឋនានាដែលអាចត្រូវបានផ្តន្ទាទោស អនុលោមតាមច្បាប់ឆ្នាំ១៩៩៤ឡើយ។ មាត្រានេះគឺសំដៅទៅលើការផ្តន្ទាទោស មិនមែនទៅលើការកាត់សេចក្តី។ វាពិតជាអាចមាន*ច្បាប់ពិសេស* (*lex specialis*) សម្រាប់ការកាត់សេចក្តី ដោយមានច្បាប់ទូទៅសម្រាប់ការផ្តន្ទាទោស។ ការបកស្រាយរបស់អង្គបុរេជំនុំជម្រះទៅលើមាត្រានេះធ្វើឲ្យវាគ្មានប្រយោជន៍អ្វីឡើយ។ ពុំចាំបាច់បញ្ចូលបញ្ញត្តិនេះក្នុងច្បាប់ឆ្នាំ១៩៩៤ឡើយ ប្រសិនបើវាគ្រាន់តែចែងអំពីអ្វីដែលអាចជារឿងពិត ដោយពុំចាំបាច់ដាក់បញ្ចូលវាក៏ដោយនោះ[64]។ ការបកស្រាយរបស់អង្គបុរេជំនុំជម្រះ ក៏មិនស្របគ្នានឹងគោលបំណងរបស់អ្នករៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យដែរ ដែលនឹងមានការពិភាក្សាបន្ថែមទៀតនៅខាងក្រោម។ លោក អៀង សារី គួរតែពុំមានបំណងទទួលយកការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋនានា ដូចមានរៀបរាប់ក្នុងច្បាប់ឆ្នាំ១៩៩៤ឡើយ ប្រសិនបើលោកនៅតែត្រូវប្រឈមមុខនឹងការកាត់ទោសចំពោះបទឧក្រិដ្ឋដូចមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាននោះ។

## ច្បាប់ឆ្នាំ១៩៩៤ - មាត្រា៥

៣១. មាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤ចែងថា៖

មាត្រា៥៖ ច្បាប់នេះអនុគ្រោះទុកពេល៦ខែ ក្រោយពីចូលជាធរមាន ឲ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុម "កម្ពុជាធិបតេយ្យ" វិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ ចំពោះបទល្មើស ដែលខ្លួនបានប្រព្រឹត្ត។[65]

៣២. មាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤អនុគ្រោះទុកពេល៦ខែឲ្យជនជាសមាជិកខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយពុំប្រឈមមុខនឹងការកាត់ទោសចំពោះបទឧក្រិដ្ឋ ដែលពួកគេបានប្រព្រឹត្ត។ មាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤ពុំបានកម្រិតបទឧក្រិដ្ឋទាំងនេះជាឧក្រិដ្ឋកម្មដែលមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៤នៃច្បាប់ឆ្នាំ១៩៩៤ឡើយ ប៉ុន្តែផ្តល់នូវការអនុគ្រោះទោសជាទូទៅដល់"គ្រប់បទល្មើសដែលខ្លួនបានប្រព្រឹត្ត"។ ចំណុចនេះមានលក្ខណៈច្បាស់លាស់ នៅពេលពិចារណាអំពីពាក្យពេចន៍ដែលគេប្រើប្រាស់ក្នុងមាត្រា៥ បើប្រៀបធៀបទៅនឹងមាត្រា៤ (មាត្រា៤

---

[64] នៅសហរដ្ឋអាមេរិក គោលការណ៍ដែលច្បាប់មួយមិនត្រូវបានបកស្រាយតាមរបៀបមួយ ដែលធ្វើឲ្យវាគ្មានន័យ ត្រូវបានបង្ហាញ៖ "រាល់ផ្នែកនីមួយៗនៃអំពើមួយ ត្រូវបានសន្មតថាមានអានុភាពខ្លះ ហើយមិនត្រូវចាត់ទុកថាពុំមានខ្លឹមសារឡើយ ប្រសិនបើមិនចាំបាច់បំផុតនោះ" *Raven Coal Corp.* ***តទល់នឹង*** *Absher*, 153 Va. 332, 335, 149 S.E. 541, 542 (ឆ្នាំ 1929)។

[65] គូសបញ្ជាក់បន្ថែម។

សំដៅទៅលើ "ប្រព្រឹត្ត" ជាជាង "បានប្រព្រឹត្ត")។ មាត្រា៤ ជាបញ្ញត្តិមួយគិតទៅមុខដែល "កំណត់ជាបទឧក្រិដ្ឋនូវបទល្មើសច្រើនជំពូក មានដូចជាបទល្មើសប្រឆាំងនឹងសន្តិសុខផ្ទៃក្នុងប្រទេស អាចជា "ការធ្វើសកម្មភាពអបគមន៍" បំផ្លាញរាជរដ្ឋាភិបាល បំផ្លាញអង្គការនៃអំណាចសាធារណៈ ឬញុះញង់ ឬបង្ខំពលរដ្ឋឲ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ គឺត្រូវទទួលការផ្តន្ទាទោសជាក់លាក់"[66]។ ផ្ទុយទៅវិញ មាត្រា៥ និយាយអំពីអតីតកាល គ្របដណ្តប់រាល់បទឧក្រិដ្ឋដែលសមាជិកនៃក្រុម "កម្ពុជាប្រជាធិបតេយ្យ"អាចបានប្រព្រឹត្តក្នុងអតីតកាល។

៣៣. ជាការគាំទ្រការយល់បែបនេះចំពោះមាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤ រហូតមកទល់បច្ចុប្បន្ននេះ ពុំមាននរណាម្នាក់ដែលបានធ្វើសមាហរណកម្មអនុលោមតាមមាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤ ត្រូវបានផ្តន្ទាទោសចំពោះរាល់បទឧក្រិដ្ឋ ដែលខ្លួនបានប្រព្រឹត្តនៅពេលជាសមាជិកនៃក្រុម"កម្ពុជាប្រជាធិបតេយ្យ"ឡើយ។ ប្រសិនបើអ្នកដែលបានវិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលអនុលោមតាមមាត្រា៥ នៅតែអាចត្រូវបានកាត់សេចក្តីក្រោមច្បាប់ព្រហ្មទណ្ឌជាធរមាន ដូចដែលអង្គបុរេជំនុំជម្រះបានបកស្រាយមាត្រា៣នោះ ពុំមានជនណាម្នាក់បានទទួលយកការអនុគ្រោះទោសនេះឡើយ។ នេះពុំអាចជាចេតនានៃបញ្ញត្តិទាំងនេះឡើយ។

## ច្បាប់ឆ្នាំ១៩៩៤ - មាត្រា៦

៣៤. មាត្រា៦នៃច្បាប់ឆ្នាំ១៩៩៤ចែងថា ការអនុគ្រោះទោសដែលចែងនៅក្នុងមាត្រា៥ពុំអាចយកមកអនុវត្តបានឡើយចំពោះមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ អនុភាពនៃព្រះរាជក្រឹត្យ ដោយសំដៅយ៉ាងច្បាស់ទៅលើច្បាប់ឆ្នាំ១៩៩៤ ក្នុងការផ្តល់ការអនុគ្រោះទោស គឺដើម្បីផ្តល់ឲ្យលោក អៀង សារី នូវការអនុគ្រោះទោសដូចគ្នានឹងការផ្តល់ការអនុគ្រោះទោសដល់សមាជិកនៃក្រុម"កម្ពុជាប្រជាធិបតេយ្យ"ផងដែរ "នៅក្នុង" ឬ"តម្រូវដោយ"[67]មាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤។ ជាសំខាន់មាត្រានេះលើកលែងលោក អៀង សារី ពីការហាមប្រាមដែលមានចែងក្នុងមាត្រា៦។ នេះគឺជាការផ្តល់ឲ្យលោក អៀង សារី នូវការអនុគ្រោះទោសពីការកាត់សេចក្តីចំពោះរាល់បទឧក្រិដ្ឋដែលគាត់អាចបានប្រព្រឹត្ត ដូចមានចែងក្នុងមាត្រា៥នៃច្បាប់ឆ្នាំ១៩៩៤។

---

[66] សាលដីការបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ១៩០។

[67] អាស្រ័យទៅលើការបកប្រែ ដែលបានប្រើប្រាស់។

### ខ. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំក្នុងការវិភាគរបស់ខ្លួនទៅលើចេតនារបស់អ្នករៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ

៣៥. អង្គបុរេជំនុំជម្រះបានយល់ឃើញថា ការបកស្រាយរបស់សហមេធាវីការពារក្តីទៅលើការអនុគ្រោះទោសថាគ្របដណ្តប់លើគ្រប់បទឧក្រិដ្ឋទាំងអស់ដែលបានប្រព្រឹត្តក្នុង "របបខ្មែរក្រហម" នឹងរំលោភចំពោះកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជាក្នុងការជំនុំជម្រះ និងផ្តន្ទាទោសចំពោះអ្នករៀបចំបង្កើតបទល្មើសទាំងនេះ និងថាពុំមានចំណុចណាមួយដែលបង្ហាញថា ព្រះមហាក្សត្រមានព្រះរាជបំណងមិនគោរពតាមកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជាឡើយ[68]។

៣៦. អង្គបុរេជំនុំជម្រះបានភ័ន្តច្រឡំដោយធ្វើការកំណត់ចេតនារបស់អ្នកចរចា និងអ្នករៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យជាទូទៅ។ អង្គជំនុំជម្រះខកខានពុំបានពិចារណាអំពីស្ថានភាពជាក់ស្តែងដែលនាំទៅរកការរៀបចំសេចក្តីព្រាង និងអនុម័តព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះឡើយ។ រដ្ឋាភិបាលកម្ពុជាបានខិតខំតស៊ូយ៉ាងខ្លាំងក្នុងការបញ្ចប់សង្គ្រាមស៊ីវិលដ៏យូរអង្វែង។ ការព្រួយបារម្ភក្នុងស្រុកដ៏លើសលុបនេះអាចមានទម្ងន់ជាងការពិភាក្សាឃោបល់ផ្នែកទ្រឹស្តី និងអរូបីយនានាដែលថា តើកម្ពុជាអាចនឹងបំពារបំពានកាតព្វកិច្ចជាអន្តរជាតិរបស់ខ្លួនក្នុងការផ្តល់ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះទេ ដែលជាបញ្ហាមួយដែលមិនត្រូវបានដោះស្រាយក្នុងច្បាប់អន្តរជាតិនៅឡើយ[69]។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានរាយការណ៍ថាបានថ្លែងថា "ដើម្បីប្រយោជន៍ជាតិ យើងត្រូវតែ [ផ្តល់ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសឲ្យលោក អៀង សារី]។ ដើម្បីបំផ្លាញ៧០%នៃកម្លាំងខ្មែរក្រហម យើងចាំបាច់ត្រូវតែប៉ាន់ចំណាយផងដែរ ពោលគឺផ្តល់ការអនុគ្រោះទោសឲ្យ អៀង សារី"[70]។

---

[68] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២០១។

[69] *សូមមើល ឧបសម្ព័ន្ធ "ខ"* ជើងទំព័រខាងលើ សម្រាប់ការពិភាក្សាអំពីថាតើការផ្តល់ការអនុគ្រោះទោសនឹងបំពារបំពានកាតព្វកិច្ចជាអន្តរជាតិរបស់រដ្ឋ ឬទេ។ ប្រសិនបើ ព្រះមហាក្សត្រព្រួយបារម្ភអំពីកាតព្វកិច្ចជាអន្តរជាតិរបស់ប្រទេសកម្ពុជា នឹងមានការធានាថា រដ្ឋាភិបាលបានអនុម័តអនុវត្តបទប្បញ្ញត្តិដើម្បីកាត់ទោសបទឧក្រិដ្ឋទាំងនេះ។ នៅគ្រានេះ ពុំមានបទប្បញ្ញត្តិអនុវត្តទូទៅ ដែលអាចអនុញ្ញាតឲ្យមានការផ្តន្ទាទោសចំពោះអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិ ដូចជា អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអ្វីឡើយ។ ច្បាប់ឆ្នាំ១៩៩៤អាចត្រូវបានពិចារណាជាបទប្បញ្ញត្តិអនុវត្ត ក្នុងការកំណត់ជាបទឧក្រិដ្ឋនូវឧក្រិដ្ឋកម្មទាំងនេះ ប៉ុន្តែមិនត្រឹមតែអនុវត្តចំពោះតែ "សមាជិកនៃក្រុមកម្ពុជាប្រជាធិបតេយ្យ" បានឡើយ។

[70] TOM FAWTHROP & HELEN JARVIS, GETTING AWAY WITH GENOCIDE: ELUSIVE JUSTICE AND THE KHMER ROUGE TRIBUNAL, ទំព័រ 137 (Pluto Press ឆ្នាំ 2004)។ Helen Jarvis, *Who Helped the Khmer Rouge to Survive?*, GREEN LEFT WEEKLY លេខ៣៤៩ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៩៩។

៣៧. ចេតនារបស់អ្នកចរចា និងអ្នករៀបចំសេចក្តីព្រាងគឺថា ព្រះរាជក្រឹត្យគ្របដណ្តប់ការកាត់សេចក្តីរាល់បទឧក្រិដ្ឋនានាដែលបានចោទប្រកាន់ថាបានប្រព្រឹត្តក្នុងអំឡុងរបបខ្មែរក្រហម។ វាពិតជាពុំមែនជាចេតនារបស់លោក អៀង សារី នោះទេ ក្នុងការចរចាសុំការអនុគ្រោះទោសដែលនឹងលើកលែងគាត់ពីការកាត់សេចក្តីក្រោមមាត្រាមួយចំនួននៃច្បាប់ឆ្នាំ១៩៩៤ ប្រសិនបើជាលោកនៅតែត្រូវបានកាត់សេចក្តីក្រោមច្បាប់ក្នុងស្រុកជាធរមាននោះ។ ព្រះរាជក្រឹត្យនេះការពារលោក អៀង សារី ពីការចោទប្រកាន់គ្រប់រូបភាពនៅថ្ងៃអនាគតចំពោះអំពើនានាដែលគាត់អាចបាន ប្រព្រឹត្តនៅក្នុងអំឡុងរបបខ្មែរក្រហម[71]។ គេចាំបាច់ត្រូវតែសន្និដ្ឋានថា ព្រះករុណាបានព្រះប្រទាន ការលើកលែងទោស និងការអនុគ្រោះទោស ជាមួយនឹងចេតនាថា រដ្ឋាភិបាលនឹងអនុវត្តទៅតាម កិច្ចព្រមព្រៀងរបស់ខ្លួនថាមិនកាត់សេចក្តីលោក អៀង សារី។ ភស្តុតាងនៃព្រឹត្តិការណ៍នេះជា អង្គហេតុដែលបានកើតឡើងក្នុងខែ សីហា ឆ្នាំ ១៩៩៨ បន្ទាប់ពីការចាប់ខ្លួនអតីតសមាជិកខ្មែរ ក្រហម នួន ប៉ែត ចំពោះសកម្មភាពរបស់គាត់ដែលជាផ្នែកមួយនៃក្រុមខ្មែរក្រហម ហើយលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាមនុស្សម្នាក់ក្នុងចំណោមអ្នកចរចា និងអ្នករៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យនោះ ត្រូវបានរាយការណ៍ថាបានបញ្ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ លោក ទៀ បាញ់ ទៅជួបជាមួយ លោក អៀង សារី និងធានាជាមួយគាត់ថា ព្រះរាជក្រឹត្យលើកលែងទោស និង អនុគ្រោះទោស ពុំមានបញ្ហាអ្វីឡើយ[72]។

៣៨. ការប្រៀបធៀបមួយអាចត្រូវបានធ្វើឡើងរវាងការចរចា និងការរៀបចំសេចក្តីព្រាងនៃព្រះរាជក្រឹត្យ និងកាតព្វកិច្ចក្នុងកិច្ចសន្យា[73]។ ការប្រៀបធៀបនេះអាចសម្រាប់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល(រួមទាំងព្រះមហាក្សត្រ) និងលោកអៀង សារី។ ជាការដោះដូរចំពោះការអនុវត្តកាតព្វកិច្ចរបស់លោក អៀង សារី ក្នុងការធ្វើសមាហរណកម្មរបស់លោកផ្ទាល់ និងអតីតសមាជិកខ្មែរក្រហមដ៏ច្រើនសន្ធឹកសន្ធាប់ ជាមួយរាជរដ្ឋាភិបាលកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់ការអនុគ្រោះទោសដល់លោក អៀង សារី ពីការកាត់សេចក្តីនៅថ្ងៃអនាគតចំពោះរាល់អំពើនានាដែលគាត់ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬក៏បានចូលរួមប្រព្រឹត្ត ក្នុងនាមជាសមាជិកនៃក្រុម

---

[71] សេចក្តីថ្លែងការណ៍របស់លោក អៀង សារី ។

[72] John A. Hall, *In the Shadow of the Khmer Rouge Tribunal: The Domestic Trials of Nuon Paet, Chhouk Rin and Sam Bith, and the Search for Judicial Legitimacy in Cambodia*, 5 LAW & PRAC. INT'L CTS. & TRIBUNALS 425 (ឆ្នាំ 2006)។

[73] Mahnoush Arsanjani *តុលាការព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់ស្តីពីការអនុគ្រោះទោសជាតិ* 93 AM. SOC'Y INT'L L. PROC. 65, 67 (ឆ្នាំ 1999)។

“ខ្មែរក្រហម”។ រាជរដ្ឋាភិបាលបានរៀបចំសេចក្តីព្រាងកាតព្វកិច្ចរបស់ខ្លួន ដោយប្រើប្រាស់ទម្រង់ជាព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសនេះ។ ក្នុងច្បាប់កិច្ចសន្យា ប្រសិនបើភាគីប្រើខ្លឹមសារដូចគ្នាចំពោះពាក្យដែលបានប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងរបស់ពួកគេ ការបកស្រាយកិច្ចព្រមព្រៀងនោះគួរធ្វើឡើងឲ្យស្របទៅតាមខ្លឹមសារនោះ បើទោះជាភាគីទីបីអាចបកស្រាយពាក្យពេចន៍នោះផ្សេងពីនេះក៏ដោយ[74]។ អ្នកចរចាអំពីការអនុគ្រោះទោសចំពោះលោក អៀង សារី យល់ពីអត្ថន័យនៃពាក្យ “ការអនុគ្រោះទោស” ដើម្បីការពារលោក អៀង សារី ពីការកាត់សេចក្តីចំពោះបទឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្តក្នុងរវាងឆ្នាំ១៩៧៥-១៩៧៩[75]។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងខាងលើ ក្រុមមេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសរារាំងមិនឲ្យមានការកាត់សេចក្តីលោក អៀង សារីនៅអង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជា។

សូមលោក-លោកស្រីចៅក្រម ទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |

សហមេធាវីរបស់លោក **អៀង សារី**

[74] ការអធិប្បាយឡើងវិញ (លើកទីពីរ)លើកិច្ចសន្យា § 201(1) (ឆ្នាំ 1979)។

[75] ក្រុមមេធាវីការពារក្តីបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកោះអញ្ជើញអ្នករៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ និងអ្នកដែលបានចូលរួមក្នុងកិច្ចចរចា ដើម្បីឲ្យមានការពន្យល់អំពីចេតនាពិតប្រាកដរបស់ពួកគេ។ ដោយអវត្តមាននៃសក្ខីកម្មនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែពឹងផ្អែកទៅលើសេចក្តីថ្លែងការណ៍របស់លោក អៀង សារី ដែលថា ការអនុគ្រោះទោសចំពោះរូបលោក និងសកម្មភាពរបស់លោកនាយករដ្ឋមន្ត្រី ក្នុងការធានាដល់លោក អៀង សារី ថា ការអនុគ្រោះទោសរបស់គាត់នៅតែមានសុពលភាព។ សូមមើល [redacted] ៩ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ E85។